# សៀវភៅមគ្គុទេសក៍
# ក្រមសីលធម៌
# និងសិទ្ធិមនុស្ស
## សម្រាប់ការងារប្រយុទ្ធប្រឆាំង
## អំពើជួញដូរមនុស្ស





### បទដ្ឋានក្រមសីលធម៌ សម្រាប់កម្មវិធី
### និងការស្រាវជ្រាវក្នុងការប្រយុទ្ធ
### ប្រឆាំងនឹងអំពើជួញដូរមនុស្ស

គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

# សៀវភៅមគ្គុទេសក៍ ក្រមសីលធម៌
# និងសិទ្ធិមនុស្ស
# សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## បទដ្ឋានក្រមសីលធម៌ សម្រាប់កម្មវិធី និងការសិក្សាស្រាវជ្រាវ
## ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

**គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស**

**បាងកក ថៃឡង់ដ៍**

**ខែកញ្ញា ២០០៨**

រក្សាសិទ្ធិ © ដោយគម្រោងអន្តរទីភ្នាក់ងាររង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ២០០៨

បោះពុម្ពលើកទី១ ឆ្នាំ២០០៨
ISBN: ៩៧៨-៩៧៨-២៥៧-២៣៣-៨

រូបក្របមុខ (ខាងលើ): ក្រុមការងាររបស់ UNIAP និង UNDPធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងភូមិមួយក្នុងប្រទេសភូមា តំបន់ស្ងួតហួតហែង (ខែមិថុនា ឆ្នាំ២០០៧)
រូបក្របមុខ (ខាងក្រោម): ក្រុមការងាររបស់ UNIAP ធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សក្នុង ភូមិមួយក្បែរព្រំប្រទល់ ឡាវ-ចិន (ខែមករា ឆ្នាំ២០០៨)

រូបក្របក្រោយ: ការប្រមូលផ្ដុំរបស់សហគមន៍ ក្នុងប្រទេសកម្ពុជា (ខែមិនា ឆ្នាំ២០០៧)

*រូបថតនៅគម្រប និងរូបថតផ្សេងទៀត ត្រូវបានថតដោយលោកស្រីបណ្ឌិត លីសា រេនឌី ថេល័រ លើកលែងតែរូបថតណាដែលមានដាក់ឈ្មោះអ្នកថត ។*

**រូបភាពទាំងឡាយក្នុងសៀវភៅមគ្គុទេសក៏ទទួលបានការគោរពបទដ្ឋានក្រមសីលធម៌ទាំងស្រុង។ រូបភាពទាំងនេះទទួលបានការយល់ព្រមពីបុគ្គល ដោយមានការបិទបាំងនូវអត្តសញ្ញាណរបស់ជនរងគ្រោះ និងជនដែលអាចជាអ្នកជួញដូរមនុស្ស។**

# មាតិកា


សេចក្តីផ្តើម៖ សេក្តីត្រូវការក្រមសីលធម៌ និងសិទ្ធិមនុស្សក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ៥

គោលការណ៍ណែនាំរបស់ UNIAP ស្តីពីក្រមសីលធម៌ និងសិទ្ធិមនុស្សក្នុងសម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញ ដូរមនុស្ស ៦

១- ជៀសវាងបង្កគ្រោះថ្នាក់៖ ចូរសម្តែងនូវការអាណិតអាសូរ ប៉ុន្តែដោយមិនលម្អៀង ១២

២- ផ្តល់អាទិភាពចំពោះសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន៖ កំណត់ និងកាត់បន្ថយគ្រោះថ្នាក់ ១៦

៣- សុំការអនុញ្ញាត ដោយគ្មានការបង្ខិតបង្ខំ ២០

៤- ធានាចំពោះការរក្សាអនាមិកភាព និងរាល់អាថ៌កំបាំងឱ្យអស់ពីលទ្ធភាព ២៧

៥- រៀបចំអ្នកបកប្រែភាសា និងក្រុមការងារឱ្យបានគ្រប់គ្រាន់ ៣៣

៦- រៀបចំព័ត៌មានបញ្ជូន និងត្រៀមខ្លួនជាស្រេចការធ្វើអន្តរាគមន៍ពេលមានភាពអាសន្ន ៣៩

៧- ជៀសវាងការស្នាក់ស្នើរក្នុងការជួយអ្នកឯទៀត៖ រៀបចំព័ត៌មានរបស់អ្នកសម្រាប់ប្រើប្រាស់ឱ្យមានប្រយោជន៍ និងត្រឹមត្រូវ ៤៤

ឧបសម្ព័ន្ធ៖ ឧបករណ៍ដើម្បីដាក់បញ្ចូលក្នុង បទដ្ឋានក្រមសីលធម៌ សម្រាប់កម្មវិធី និងការសិក្សាស្រាវជ្រាវក្នុងការ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ៤៧

ឧបសម្ព័ន្ធ១. ទម្រង់វាយតម្លៃក្រមសីលធម៌របស់ UNIAP ក្នុងការសិក្សាស្រាវជ្រាវក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញ ដូរមនុស្ស ៤៨

ឧបសម្ព័ន្ធ២. វិក្កប័ត្រចំណាយ ដោយការយល់ព្រមដើម្បីផ្តល់ព័ត៌មាន ៥២

ឧបសម្ព័ន្ធ៣. គោលការណ៍ណែនាំស្តីពីការយល់ព្រមធ្វើសាក្សីដោយពាក្យសម្តី ៥៤

ឧបសម្ព័ន្ធ៤. ប្រការគប្បី និងមិនគប្បីប្រព្រឹត្តរបស់ UNIAP ក្នុងការងារក្នុងមូលដ្ឋាន ៥៨

# សេចក្តីផ្តើម

## សេចក្តីត្រូវការក្រមសីលធម៌ និងសិទ្ធិមនុស្សសម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

ក្នុងឆ្នាំ២០០៣អង្គការសុខភាពពិភពលោកបានចេញផ្សាយគោលការណ៍ណែនាំចំនួនដប់សម្រាប់សម្ភាសន៍ស្ត្រីរងគ្រោះដោយអំពើជួញដូរ។ គោលការណ៍ណែនាំទាំងនេះជាជំហានវិជ្ជមានដើម្បីធានាថាសិទ្ធិរបស់ស្ត្រីជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស[១] ត្រូវបានគោរពក្នុងខណៈធ្វើការសិក្សាស្រាវជ្រាវ និងការធ្វើសម្ភាសន៍ជនរងគ្រោះ។ ជាមួយគោលការណ៍ណែនាំតាមបែបកុមារមេត្រីរបស់អង្គការ UNICEF [២] គោលការណ៍ទាំងនេះ នៅតែជាគោលការណ៍ណែនាំដ៏មានសារៈសំខាន់សម្រាប់អ្នកប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សប្រើប្រាស់ដើម្បីធ្វើការជាមួយអ្នករងគ្រោះដោយអំពើនេះ។ ផ្ទុយទៅវិញ ចាប់តាំងពីរយៈពេលដែលគោលការណ៍ណែនាំនេះបានចេញផ្សាយមក យើងបានយល់ឃើញថាស្ថានភាពមួយចំនួនក្នុងការសិក្សាស្រាវជ្រាវ និងធ្វើកម្មវិធីដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅមិនទាន់បានដោះស្រាយក្នុងលក្ខណៈទូលំទូលាយនៅឡើយ ជាអាទិ៍ :

[១] អង្គការសុខភាពពិភពលោក (២០០៣). អនុសាសន៍ក្រមសីលធម៌ និងសុវត្ថិភាពសម្រាប់សម្ភាសន៍ស្ត្រីរងគ្រោះដោយអំពើជួញដូរ។

[២] មូលនិធិកុមារអង្គការសហប្រជាជាតិ(២០០៦). គោលការណ៍ណែនាំលើការការពារកុមាររងគ្រោះដោយអំពើជួញដូរ។

[៣] អង្គការសហប្រជាជាតិ ពុំមានគណកម្មការពិនិត្យ ឬគោលការណ៍ណែនាំសម្រាប់អនុវត្តប្រកបដោយក្រមសីលធម៌ចំពោះការសិក្សាស្រាវជ្រាវដូចដែលធ្លាប់មាននៅក្នុងគ្រឹះស្ថាន អប់រំ និងក្រុមប្រឹក្សាជាតិស្រាវជ្រាវទេ។ ឧទាហរណ៍នៃក្រុមប្រឹក្សានេះមានសរសេរនៅក្នុងប្រការទី៨របស់គោលការណ៍ណែនាំនេះ គឺធានាចំពោះការរក្សាអនាមិកភាព និងរាល់អាថ៌កំបាំងឱ្យអស់ពីលទ្ធភាព

- តើអ្វីជាខ្លះជាក្រមសីលធមិក្នុងការធ្វើសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សជាបុរស?
- តើអ្វីជាខ្លះជាក្រមសីលធមិក្នុងការធ្វើសម្ភាសន៍ឬធ្វើកម្មវិធីដែលពាក់ព័ន្ធទៅនឹងក្រុមគ្រួសារ ឬអ្នកជិតខាងដែលអាចជាជនរងគ្រោះ ឬជាជនល្មើស ជាពិសេសបញ្ហាស្លាកស្នាមទូរយស៍ និងការពិត ដែលថាសាច់ញាតិឬអ្នកជិតខាងអាចជាប់ទាក់ទងទៅនឹងបទល្មើស?
- តើអ្វីជាខ្លះជាក្រមសីលធមិក្នុងការធ្វើសម្ភាសន៍ឬការអនុវត្តកម្មវិធីដែលពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលកំពុងធ្វើការក្នុងស្ថានភាពគ្រោះថ្នាក់នោះ?

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតដែលចាំបាច់នេះ គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស (UNIAP) បានចាប់ផ្តើមចេញផ្សាយក្រមសីលធម៌ និងសិទ្ធិមនុស្សសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើនេះហើយ ដើម្បីបំពេញតម្រូវការក្នុងមហាសហគមន៍ ស្របទៅនឹងតួនាទីរបស់ UNIAP ដែលជាអង្គភាពសម្របសម្រួលជាអ្នកដឹកនាំ និងអ្នកផ្តល់សេវាបច្ចេកទេស ជាពិសេសក្នុងប្រទេសទាំងប្រាំមួយ[៨] ក្នុងមហាអនុតំបន់ទន្លេមេគង្គ។ សៀវភៅមគ្គុទេសក៏នេះជាផ្នែកមួយក្នុងកិច្ចផ្តួចផ្តើមដ៏ធំមានគោលបំណង :

- ឆ្លើយតបនឹងតម្រូវការគោលការណ៍ណែនាំសំខាន់ៗដែលមានលក្ខណៈទូលំទូលាយ និងថ្មីៗដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធី ចំពោះក្រុមមនុស្សទាំងឡាយដែលពាក់ព័ន្ធ រួមមានទាំងក្រុមបុរស សហគមន៍ និងជនរងគ្រោះដោយអំពើជួញដូរ ក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់។

---

៨ ការិយាល័យប្រទេសទាំង៦របស់ UNIAPមាននៅក្នុងប្រទេស កម្ពុជា ចិន ឡាវ ភូមា ថៃ និងវៀតណាម ហើយការិយាល័យប្រចាំតំបន់នៅទីក្រុងបាងកក

- អនុវត្តគោលការណ៍ណែនាំក្រមសីលធម៌ និងសិទ្ធិមនុស្សចំនួន៧សម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ និងឧបករណ៍អនុវត្តមួយចំនួនដើម្បីប្រើប្រាស់ដោយអ្នកសិក្សាស្រាវជ្រាវ អ្នកអនុវត្តកម្មវិធីរបស់ UNIAP ដែលធ្វើការជាមួយជនរងគ្រោះ និងអ្នកដែលទទួលរងប៉ះពាល់ដោយអំពើជួញដូរ។

- បង្កើតឧបករណ៍មានភាពងាយស្រួលដើម្បីជួយដល់អ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តកម្មវិធីក្នុងសកម្មភាពប្រចាំថ្ងៃប្រកបដោយក្រមសីលធម៌និងដើម្បីគ្រេបជញ្ជក់បង្កើនចំណេះដឹង និងគិតគូរសិទ្ធិមនុស្សជាមូលដ្ឋាន ដូចជាការស្នើសុំសេចក្ដីយល់ព្រម ការរក្សាការសម្ងាត់ និងភាពគ្មានការបង្ខិតបង្ខំឡើយ ។
- ផ្សព្វផ្សាយគោលការណ៍ណែនាំ និងរាល់ឧបករណ៍ទៅកាន់ដៃគូរ និងម្ចាស់ជំនួយទូទាំងពិភពលោកដើម្បីសាកល្បងផ្ដល់ព័ត៌មានត្រឡប់ និងអនុវត្តក្នុងគោលបំណងលើកស្ទួយការគោរព ក្រមសីលធម៌ និងសិទ្ធិមនុស្សជាមូលដ្ឋានឱ្យបានទូលំទូលាយក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរនេះ។

តាងនាមជាគម្រោងអន្តរទីភ្នាក់ងារអង្គការ UNIAP ធ្វើការជាមួយក្រុមអ្នកធ្វើការងារពាក់ព័ន្ធ និងដៃគូរទាំងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារ និងគម្រោងរបស់អង្គការសហប្រជាជាតិ បណ្ដាទីភ្នាក់ងារឯទៀត, គ្រឹះស្ថានអប់រំសិក្សា អង្គទូត និងសហគមន៍អ្នកផ្ដល់ជំនួយ។ មិនខុសពីរាល់គំនិតផ្ដួចផ្ដើមទាំងឡាយរបស់ UNIAP ឡើយ សៀវភៅមគ្គុទេសក៍ ក្រមសីលធម៌ និងសិទ្ធិមនុស្សសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរនេះបានទទួលជំនួយបច្ចេកទេសពីបណ្ដាដៃគូរ និងសហសេវិកសំខាន់ៗ ទាំងអស់ជុំវិញពិភពលោកផងដែរ។

សៀវភៅមគ្គុទេសក៏នេះរៀបរៀង និងនិពន្ធដោយបណ្ឌិត លីសា រេនឌីថេល័រ ដោយមានការចូលរួមចំណែកពុំអាចកាត់ថ្លៃបានពីលោក ម៉ាធូ ហ្វ្រេតមែន ផូល បាកលី និងអូយវីន ហូយេន ក្រុមបច្ចេកទេសរបស់ UNIAP ប្រចាំតំបន់។ មេលីសា ប្រេណាន់ (ច្បាប់ មកពីសាលាប្រូកលីន) លីសា លី (ច្បាប់ មកពីសាលា ហារីដ) និងបណ្ឌិត ដួយ វ៉ាង (ច្បាប់ មកពីសាលា ហារីដ) ជាក្រុមការងារផ្នែកច្បាប់កម្មសិក្សាពេលវិស្សមកាល និងអ្នកសម្របសម្រួល គម្រោងថ្នាក់ជាតិរបស់ UNIAP មានលោក លឹម ទិត្យ (កម្ពុជា) លោកស្រីអុម៉ា អេ អេចាវ (ភូមា) និងបណ្ឌិត រាចាដា ចាយ៉ាគុបតា(ថៃ)។ ដោយឡែកវិញទៀតក៏សូមថ្លែងអំណរគុណចំពោះការជួយឧបត្ថម្ភគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងស្មារតីពីក្រុមការងារទាំងអស់របស់ការិយាល័យ UNIAP ប្រចាំតំបន់ គឺ ផនីផា ប៊ូឌី និងអូណាណុង អាណាម៉ាន។

សូមថ្លែងអំណរគុណជាពិសេសសម្រាប់ជំនួយបច្ចេកទេស និងស្មារតីចំពោះបណ្ឌិត ដេវីដ ហ្វេនហ្គូល ពីអង្គការ យូណេស្កូ ក្រុងបាងកក អាឡាន់ ប៊ីស៊ី ដាណាំង/វៀតណាម/មែលបួន និង ចន ហ្វ្រេដីរិក ពីពន្លឺនៃក្ដីសង្ឃឹម ពីទីក្រុង កាតាម៉ាន់ឌូ។ សូមអរគុណចំពោះក្រុមការងារលើគម្រោងសាកល្បង ក្នុងគំនិតផ្តួចផ្តើមប្រកួតប្រជែងធ្វើការប៉ាន់ប្រមាណអំពើជួញដូរមនុស្សរបស់UNIAP ហើយសៀវភៅមគ្គុទេសក៏នេះត្រូវបានប្រើប្រាស់ មានបណ្ឌិ ថម៉ាស់ ស្ដេនហ្វាត ពីសកលវិទ្យាល័យ ម៉ៃអេមី បណ្ឌិត ខួតឡេន វ៉ីបីនសុន និងឆាឡុត ដូឡិន ពីសាលាសុខភាព សាធារណៈ ចន ហប់ខីន បណ្តាញក្រុមអ្នកលើកស្ទួយសិទ្ធិពលករក្នុងប្រទេសថៃ និង លីលី ផនអាងយ៉ាង ដុង ថាប់ សម្ព័ន្ធភាពដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សក្នុងប្រទេសវៀតណាម។

ជាទីបញ្ចប់ យើងគួរតែចងចាំថាបើអនុវត្តតាមសៀវភៅមគ្គុទេសក៏នេះតែមួយមុខនោះ វាមិនទាន់គ្រប់គ្រាន់ក្នុងការធានាបាននូវក្រមសីលធមិសម្រាប់ការសិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សទេ។ ចាំបាច់យើងត្រូវធ្វើផែនការរៀបចំឱ្យបានល្អិតល្អន់ និងធ្វើការបណ្ដុះបណ្ដាលរាល់កម្មវិធី និងការសិក្សាស្រាវជ្រាវច្បាស់លាស់។

យើងត្រូវដឹងថាមិនមែនមនុស្សគ្រប់រូបអាចប្រឈមទៅនឹងការសិក្សាស្រាវជ្រាវ ឬធ្វើកម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើនេះបានទេ។ ផ្ទុយទៅវិញសម្រាប់អ្នកអាចធ្វើបាននោះយើងសង្ឃឹមថាសៀវភៅមគ្គុទេសក៏នេះអាចជួយផ្តល់ជាគោលការណ៍ណែនាំសំខាន់ៗដើម្បីអនុវត្តក្នុងភារកិច្ចនេះ។

*ក្រុមការងារថ្នាក់តំបន់ របស់* ***UNIAP***

*បាងកក ប្រទេសថៃ*

*ខែកញ្ញា ឆ្នាំ២០០៨*



Children in a village in Kandal province, Cambodia

# គោលការណ៍ណែនាំសំខាន់ៗ

## ក្រមសីលធម៌ និងសិទ្ធិមនុស្ស សម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

១- ជៀសវាងបង្កគ្រោះថ្នាក់: ចូរសម្តែងនូវការអាណិតអាសូរ ប៉ុន្តែដោយមិនលម្អៀង

២- ផ្តល់អាទិភាពចំពោះសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន: កំណត់ និងកាត់បន្ថយគ្រោះថ្នាក់

៣- សុំការអនុញ្ញាតិ ដោយគ្មានការបង្ខិតបង្ខំ

៤- ធានាចំពោះការរក្សាអនាមិកភាព និងរាល់អាថ៌កំបាំងឱ្យអស់ពីលទ្ធភាព

៥- រៀបចំអ្នកបកប្រែភាសា និងក្រុមការងារឱ្យបានគ្រប់គ្រាន់

៦- រៀបចំព័ត៌មានបញ្ជូន និងត្រៀមខ្លួនជាស្រេចការធ្វើអន្តរាគមន៍ពេលមានភាពអាសន្ន

៧- ជៀសវាងការស្ទាក់ស្ទើរក្នុងការជួយអ្នកឯទៀត: រៀបចំព័ត៌មានរបស់អ្នកសម្រាប់ប្រើប្រាស់ ឱ្យមានប្រយោជន៍ និងត្រឹមត្រូវ

# ១- ជៀសវាងបង្កគ្រោះថ្នាក់: សម្តែងនូវការអាណិតអាសូរ ប៉ុន្តែដោយមិនលម្អៀង

## តើអ្នកសិក្សាស្រាវជ្រាវ ឬអ្នកអនុវត្តកម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស អាចបង្កគ្រោះថ្នាក់បានដោយរបៀបណា?

ត្រូវគិតថាទង្វើមួយចំនួនរបស់យើងអាចបង្កឱ្យមានអសន្តិសុខ ការប៉ះពាល់ផ្លូវអារម្មណ៍និងផ្នែកសង្គមដល់អ្នកចូលរួមក្នុងការធ្វើការសិក្សាស្រាវជ្រាវ ឬអ្នកទទួលផលពីកម្មវិធី ហើយយើងត្រូវទប់ស្កាត់ផលអវិជ្ជមាននេះ។

## នៅពេលកំពុងធ្វើសម្ភាសន៍...

☑ ***សួរខ្លួនឯងនូវសំណួរខាងក្រោមនេះ :***

- បើខ្ញុំសម្ភាសន៍អ្នកត្រូវគេជួញដូរ (ឬក្នុងកម្មវិធី)តើមានសន្តិសុខ ការប៉ះពាល់ផ្លូវអារម្មណ៍ គ្រោះថ្នាក់ផ្នែកសង្គមសេដ្ឋកិច្ច ឬគ្រោះថ្នាក់ដទៃទៀតដែលអាចធ្លាក់ទៅលើពួកគេដែរឬទេ?
- បើខ្ញុំសម្ភាសន៍(ឬក្នុងកម្មវិធីរបស់ខ្ញុំ) ក្រុមគ្រួសារ ញាតិសណ្តាន ឬអ្នកភូមិផងរបងជាមួយរបស់អ្នកធ្វើនិសន្តប្រវេសន៍ដែលអាចជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស តើទង្វើនេះបង្កគ្រោះថ្នាក់ដែរឬទេ?

## ☑ *ពិនិត្យមើលបញ្ជីប្រការចៀសវាងគ្រោះថ្នាក់*

- *គោរពសិទ្ធិរបស់អ្នកចូលរួម* តើអ្នកបានធ្វើការសន្មតទុកជាមុនចំពោះអ្នកចូលរួមដែរឬទេ? តើអ្នកបានត្រៀមខ្លួនជាស្រេចដើម្បីស្តាប់រឿងរ៉ាវដែលមិនបានរំពឹងទុកហើយឬនៅ? ប្រសិនបើដូច្នោះមែន ចូរសម្រួលគំនិតរបស់អ្នកវិញ។
- *សម្លឹងមើលជុំវិញខ្លួន* តើមានម៉ាស៊ីនសន្តិសុខដែរឬទេ? តើមានអ្នកចាំស្តាប់ក្នុងការសន្ទនានោះដែរឬទេ? តើបុគ្គលដែលអ្នកនឹងសម្ភាសន៍មានអារម្មណ៍យ៉ាងដូចម្តេចដែរ? ធម្មតា ឬតក់ស្លុត? បើមានដូចរៀបរាប់មកខាងដើមនោះ អ្នកត្រូវរកកន្លែងណាដើម្បីធានារឿងសម្ងាត់ផ្ទាល់ខ្លួន និងមានភាពងាយស្រួល ឬក៏ផ្អាកកិច្ចសម្ភាសន៍ប្រសិនបើមានអារម្មណ៍ថាលំបាកនោះ។
- *ស្វែងយល់ពីសន្តិសុខ និងបរិយាកាសសង្គម*

  តើមានសញ្ញាបង្ហាញខ្លះដែរឬទេថាការសម្ភាសន៍របស់លោកអ្នករឹតតែបង្កើនអសន្តិសុខ ដូចជាមានការចងគំនុំ ឬសងសឹក

  ពីសំណាក់ និយោជក មេការ សមាជិកគ្រួសារ សមាជិកសហគមន៍ អាជ្ញាធរ ឬអ្នកណាម្នាក់ដែរឬទេ? ប្រសិនបើមានការសង្ស័យ ចូរសម្រេចផ្អាកការសម្ភាសន៍ឬរៀបចំការណាត់ជួបជាថ្មី ឬធ្វើការផ្លាស់ប្តូរទីណាត់ជួប។
- *ស្វែងយល់ពីការរំពឹងទុករបស់អ្នកផ្តល់បទសម្ភាសន៍/អ្នកទទួលផលពីកម្មវិធី* តើអ្នកបានធ្វើអ្វីមួយដែលឱ្យអ្នកផ្តល់សម្ភា-សន៍រំពឹងថា បន្ទាប់ពីនេះទៅនឹងទទួលបានអ្វីមួយ ប៉ុន្តែបែរជាមិនបានវិញដែរឬទេ? ត្រូវដឹងថាបញ្ហានេះអាចកើតមាន។ ចូរពន្យល់អ្នកផ្តល់ការធ្វើសម្ភាសន៍យល់ឱ្យច្បាស់ពីកិច្ចពិភាក្សា និងគោលបំណង។
- *យកចិត្តទុកដាក់ចំពោះឥរិយាបទរបស់អ្នក និងចម្លើយដែលទទួលបាន*

  តើអ្នកសួរសំណួរប្រកបដោយភាពមិនលម្អៀងដែរឬទេ? តើការបញ្ចេញទឹកមុខ និងការបញ្ចេញកាយវិការរបស់អ្នកបង្ហាញពីអព្យាក្រិតភាព និងដោយគ្មានការវាយតម្លៃដែរឬទេ? វាមានសារសំខាន់ណាស់ក្នុងការហ្វឹកហាត់ធ្វើសម្ភាសន៍ និងទទួលយកការរិះគន់ពីមិត្តរួមការងារដែលមានបទពិសោធន៍លើឥរិយាបថរបស់អ្នក។ ទង្វើនេះអ្នកនឹងភាពងាយស្រួលក្នុងការចៀសវាងឥរិយាបទអវិជ្ជមានក្នុងការធ្វើសម្ភាសន៍ពិតៗ។

## *នៅពេលរៀបចំព្រឹត្តិការ/រៀបចំកម្មវិធី ត្រូវធានាថា...*

☑ *ព័ត៌មានពីអ្នកទទួលផលពីកម្មវិធី*

ត្រូវបានយកចិត្តទុកដាក់ដើម្បីធានាថាការរៀបចំព្រឹត្តិការ/កម្មវិធីទទួលបានសេចក្តីត្រូវការផ្ទាល់ខ្លួន និងប្រកបដោយភាពងាយស្រួល។

☑ គ្មានអ្វីដែលអាចសម្របសម្រួលដើម្បីដោះដូរជាមួយនឹង*ការសម្ងាត់*របស់ជនរងគ្រោះដោយអំពើជួញដូរឬក្រុមគ្រួសាររបស់គេឡើយ។

☑ *សារព័ត៌មាន* ប្រសិនបើមានការចូលរួមពីបណ្តាសារព័ត៌មាន ចូរយល់អំពីក្រមសីលធម៌ និងការសម្រេចចិត្តដែលពាក់ព័ន្ធពីសិទ្ធិចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

☑ ព្រឹត្តិការ/កម្មវិធី *មិនត្រូវរើសអើងចំពោះជនរងគ្រោះដោយការជួញដូរ*នោះទេ។ ចូរធ្វើការប្រឹក្សា ឬសុំការអនុញ្ញាតជាមុនសិនមុនពេលស្តាប់រឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះ។

☑ *ការប៉ាន់ប្រមាណលើផលប៉ះពាល់* ត្រូវមានការគិតពិចារណា ដើម្បីបង្ហាញថាសកម្មភាពនោះមិនបានផ្តល់ភាពងាយរងគ្រោះ និងឬបន្ថែមបន្ទុកមួយទៀតដល់ស្ថានភាពបច្ចុប្បន្ននោះទេ។

**ការបំពាន "ប្រការជៀសវាង" :**

**វិស័យសារព័ត៌មានក្រោយពេលព្យុះសមុទ្រយក្ស ស៊ូណាមី ក្នុងប្រទេសឥណ្ឌូណេស៊ី**

ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៤ព្យុះកំណាចយក្ស ស៊ូណាមីកើតឡើងក្នុងប្រទេសឥណ្ឌូណេស៊ី បន្ទាប់មកមានអង្គការមនុស្សធម៌ និងអភិវឌ្ឍន៍។ ជាអកុសលមានរបាយការណ៍ដោយគ្មានការទទួលខុសត្រូវ មកដល់អ្នកសារព័ត៌មានធ្វើឡើង ភ្នាក់ងារអន្តរជាតិមួយ ដែលធ្វើការការពារកុមារ រាប់បញ្ចូលទាំងកុមារត្រូវគេជួញដូរផងដែរ។

មុនពេលករណីជួញដូរត្រូវបានបង្ហាញភស្តុតាងពិតប្រាកដ ទីភ្នាក់ងារនោះបានរាយការណ៍ពីករណីនៃការជួញដូរកុមារ ទៅក្នុងតំបន់រងគ្រោះដោយ ស៊ូណាមី។ ជាលទ្ធផល មានការបង្រ្កាបលើមនុស្សពេញវ័យដែលព្យាយាមជួយកុមារដែលត្រូវ ជាក្មួយ

និងបងប្អូនជីដូនមួយរបស់ពួកគេដែលឪពុកម្តាយបានស្លាប់ចោល ។ ការយកចិត្តទុកដាក់លើបញ្ហាជួញដូរមនុស្សតែមួយមុខគត់នោះបណ្តាលឱ្យការយកចិត្តទុកដាក់លើបញ្ហាចំបងៗដែលត្រូវដោះស្រាយភ្លាមៗខកខាន មានជាអាទិ៍ម្ហូបអាហារដើម្បីទប់ទល់នឹងសេចក្តីស្រេកឃ្លាន ទុរភិក្ស ថ្នាំសង្កូវដើម្បីព្យាបាលរោគជាដើម។

ប្រតិកម្មពីភ្នាក់ងារអភិវឌ្ឍន៍ទៀតបានលើកយកឥទ្ធិពលអវិជ្ជមានរបស់របាយការណ៍ដែលគ្មានអំណះអំណាងគ្រប់គ្រាន់ដើម្បីបន្ថុចបង្អាក់គោលបំណងវិជ្ជមានទៅវិញ។

**ការបំពាន "ប្រការជៀសវាង" :**

**ការរៀបចំកម្មវិធីសម្រាប់ផ្តល់ជម្រើសមធ្យោបាយចិញ្ចឹមជីវិតនៅក្នុងប្រទេសកម្ពុជា**

ការធ្វើអន្តរាគមន៍ក្នុងទីប្រជុំជនមួយចំនួនក្នុងប្រទេសកម្ពុជាបានព្យាយាមផ្តល់ជំនាញឱ្យស្ត្រីនៅក្នុងឧស្សាហកម្មផ្លូវភេទដើម្បីឱ្យពួកគេអាចចាកចេញពីអាជីវកម្មផ្លូវភេទទៅរកអាជីពមួយមួយផ្សេងវិញ។ កម្មវិធីនេះបានជ្រើសរើសស្ត្រីរកស៊ីផ្លូវភេទឱ្យទទួលយកជំនាញតុបតែងមុខ និងអនុវត្តផ្ទាល់នៅក្នុងហាងកែសម្ផស្ស។ ស្ត្រីទាំងនោះបានបោះបង់នូវអាជីវកម្មផ្លូវភេទចេញដើម្បីទទួលឱកាស បណ្តុះបណ្តាលពេញម៉ោង និងបន្ទាប់មកក្លាយជាកូនជាងក្រោមការសន្យាពីថៅកែហាងនោះ។

តាមការវាយតម្លៃក្នុងកម្មវិធីនេះយើងឃើញថាស្ត្រីទាំងនោះទទួលការបណ្តុះបណ្តាល និងធ្វើជាកូនជាងអស់រយៈពេល ១៦ ខែ ដោយគ្មានទទួលកម្រៃសោះ។ ស្ត្រីទាំងនោះពន្យល់ថាពួកគេធ្វើការពេញម៉ោងនៅក្នុងហាងប៉ុន្តែថៅកែជាអ្នកទទួលប្រាក់ទៅវិញ។ ក្នុងអំឡុងស្ត្រីទាំងអស់ធ្វើការដោយគ្មានប្រាក់ចំណូលសោះនោះ ។ ពួកគាត់មួយចំនួនបានវិលត្រឡប់ទៅប្រកបផ្លូវភេទវិញ។ ការត្រឡប់ទៅកាន់កន្លែងចាស់វិញនោះធ្វើឱ្យពួកគាត់បាត់បង់នូវអតីតភាពរបស់គេក្នុងការទទួលបំណែង ចែកប្រាក់កម្រៃ ហើយស្ថានភាពរបស់ពួកគេលំបាកជាងពីមុនពេលចាកចេញទៅទៀត។ ពួកគាត់រៀបរាប់ពីការអាក់អន់ស្រពន់ ចិត្តទៅនឹងការលើកឡើងថា ជំនាញវិជ្ជាជីវៈនឹងធ្វើឱ្យគេទទួលបានការថ្មីល្អមួយសម្រាប់អនាគត។ ផ្ទុយទៅវិញពួកគេគ្មានប្រាក់ដើម្បីទិញសម្ភារៈយកមកអនុវត្ត ហើយគ្មានដើមទុនក្នុងការបង្កើតរបរនេះទាល់តែសោះ លើកលែងតែពួកគេទៅទទួលភ្ញៀវ នៅផ្ទះបនដើម្បីយកប្រាក់នៅរាត្រីកាលតែប៉ុណ្ណោះ។

ទាំងថៅកែហាងសម្អាង និងអ្នកសម្របសម្រួលកម្មវិធី (និយោជិតរបស់ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិមួយ) សុទ្ធតែអះអាងថានេះជាឱកាសសម្រាប់ស្ត្រីរកស៊ីផ្លូវភេទពីមុននោះ។

ទីបំផុតស្ត្រីទាំងនេះមានការប្រឈមនឹងគ្រោះថ្នាក់ចំពោះឥទ្ធិពលផ្នែកសង្គម សេដ្ឋកិច្ច អារម្មណ៍ និងសុខភាព ។

# ២- លើកអាទិភាពចំពោះសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន: កំណត់ និងកាត់បន្ថយគ្រោះថ្នាក់

## ការរៀបចំកម្មវិធី និងការស្រាវជ្រាវនៅលើបទឧក្រិដ្ឋដូចជាការជួញដូរមនុស្សនាំឱ្យមានការប្រឈមមុខចំពោះគ្រោះថ្នាក់

ការធ្វើអន្តរាគមន៍ និងសកម្មភាពស៊ើបអង្កេតចំពោះអ្នករកស៊ីនឹងអំពើជួញដូរមនុស្សអាចធ្វើឱ្យអ្នកអនុវត្តការងារប្រឆាំងនឹងអំពើនេះ ប្រឈមមុខទៅក្នុងភាពគ្រោះថ្នាក់។ ហើយការលុបបំបាត់គ្រោះថ្នាក់នេះមិនអាចធ្វើបានទេ ហេតុដូចនេះហើយ សុវត្ថិភាពផ្ទាល់ខ្លួន ត្រូវតែជាអាទិភាពចម្បង ហើយគ្រោះថ្នាក់នោះត្រូវកំណត់ និងកាត់បន្ថយឱ្យតិចបំផុត។

☑ ***ប៉ាន់ប្រមាណទំហំរបស់គ្រោះថ្នាក់*** *ចូរធ្វើផែនការដោយប្រុងប្រយ័ត្នក្នុងការធ្វើការសិក្សាស្រាវជ្រាវ និងកិច្ចខិតខំប្រឹងប្រែងចំពោះការធ្វើការអន្តរាគមន៍របស់អ្នក ហើយត្រូវស្វែងយល់អំពីគ្រោះថ្នាក់អាចជាប់ពាក់ព័ន្ធ*

- ពិចារណាទៅលើទីកន្លែងដែលអ្នកនឹងអនុវត្តការងារ និងក្រុមមនុស្សដែលអាចបង្កគ្រោះថ្នាក់បាន។ តើការងាររបស់អ្នកតម្រូវឱ្យអ្នកធ្វើដំណើរនៅពេលយប់ដែរឬទេ? តើអ្នកមានអ្នកអមដំណើរដើម្បីជួយរក្សាសន្តិសុខ (នគរបាល ឬអង្គការក្រៅរដ្ឋាភិបាល) ដែរឬទេ? តើអ្នកធ្វើការសហការជាមួយនរណាខ្លះ?

- ធ្វើការប្រឹក្សាជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (NGOs) នគរបាល មន្រ្តីក្នុងស្រុក និងឬបុគ្គលមួយចំនួន ដើម្បីស្វែងយល់ពីស្ថានភាពសន្តិសុខនៅកន្លែងដែលធ្វើការសិក្សាស្រាវជ្រាវ ឬធ្វើកម្មវិធី។ ស្វែងយល់អំពីវត្តមានរបស់អ្នកនៅទីនោះត្រូវបានគេដឹងដែរឬទេ។
- មិនត្រូវបន្តធ្វើការសិក្សាស្រាវជ្រាវ ឬធ្វើអន្តរាគមន៍ដែលបង្កឱ្យមានអសន្តិសុខចំពោះអ្នក និងអ្នកឯទៀត។

☑ ***ធ្វើការកាត់បន្ថយភាពងាយរងគ្រោះថ្នាក់***

- ត្រូវស្គាល់បរិយាកាសជុំវិញខ្លួន។ ប្រើប្រាស់ផែនទីជាជំនួយ និងឬសាកសួរអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (NGOs) ឬមន្រ្តីរដ្ឋាភិបាលដើម្បីឱ្យអ្នកស្គាល់ទីកន្លែងនោះ។
- សង្កេតជានិច្ចថាតើអ្នកមានគេឃ្លាំមើល ឬតាមពីក្រោយខ្នង។
- ធ្វើការជាមួយដៃគូរនៅពេលដែលចាំបាច់។ ប្រសិនបើធ្វើការតែម្នាក់ឯងដោយខានពុំបាននោះ ត្រូវប្រាកដថាអ្នកឯទៀតបានដឹងអំពីផែនការ និងទីកន្លែងដែលអ្នកធ្វើដំណើរទៅ។
- ត្រូវមានទូរស័ព្ទចល័ត ឬវិទ្យុទាក់ទងដែលអាចធ្វើការទាក់ទងគ្នាបានជាមួយអាជ្ញាធរដែនដី។

☑ ***ត្រៀមខ្លួនសម្រាប់ស្ថានភាពមានអាសន្ន និងរកទីជម្រកសុវត្ថិភាពនៅពេលចាំបាច់***

- នៅស្មៀម

- បន្តការធ្វើការទាក់ទងជាមួយក្រុមការងារ ក្រុមរដ្ឋអំណាចមូលដ្ឋាន មន្ត្រីរដ្ឋាភិបាល និងទាក់ទងជាមួយសហគមន៍នៅទីនោះ។

# ការអនុវត្តល្អ និងបទពិសោធន៍ : សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន

## ការអនុវត្តល្អនៅសមុទ្រសាខន ប្រទេសថៃ : បុគ្គលិកប្រចាំការនៅពេលអ្នកសិក្សាស្រាវស្ថិតនៅតំបន់គ្រោះថ្នាក់

បណ្តាញអង្គការក្រៅរដ្ឋាភិបាលថៃដើម្បីលើកស្ទួយសិទ្ធិពលករ (LPN) និងអ្នកសិក្សាស្រាវជ្រាវពីសាលាសុខភាពសាធារណៈ ចន ហាប់ឃីន បានរួមកម្លាំងដើម្បីធ្វើការសិក្សាស្រាវជ្រាវលើចំនួនអ្នករងគ្រោះដោយអំពើជួញដូរ សម្រាប់កេងប្រវ័ញ្ចពលកម្មមកពីប្រទេសភូមា នៅខេត្ត សាមុត សាខន ប្រទេសថៃ។ បន្ទាប់ពីការធ្វើការប៉ាន់ប្រមាណលើភាពងាយរងគ្រោះថ្នាក់ ក្រុមការងារបានរៀបចំពិធីការសម្រាប់ស្ថានភាពលំបាកលំបិននេះដោយមានបុគ្គលិកប្រចាំការនៅឯការិយាល័យ ដោយធ្វើការទាក់ទងគ្នាដោយទូរស័ព្ទក្នុងខណក្រុមការងារកំពុងបំពេញភារកិច្ចនៅទីកន្លែង។ តួនាទីសំខាន់ៗនៃបុគ្គលិកប្រចាំការត្រូវផ្តល់ជំនួយជាបន្ទាន់ក្នុងករណីចាំបាច់ ដោយធ្វើការផ្តល់និងតាមដានព័ត៌មានជាមួយនគរបាល មន្ទីរព្យាបាល និងផ្នែកផ្សេងៗទៀត។

អ្នកស្រាវជ្រាវក៏ពិនិត្យមើលភាពប្រថុយគ្រោះថ្នាក់លើទីកន្លែងធ្វើការសិក្សាស្រាវជ្រាវជាមុនសិនដើម្បីសន្តិសុខ និងធ្វើការសិក្សាស្រាវជ្រាវនៅទីកន្លែងណាដែលធានាសុវត្ថិភាព និងមានឯកជនភាពហើយកាន់យកទូរស័ព្ទដៃទៅ ជាមួយរាល់ពេលវេលា។

# ការអនុវត្តល្អ និងបទពិសោធន៍ ៖ សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន

### បទពិសោធន៍ពី គុលកាតា ប្រទេសឥណ្ឌា ៖

### ជានិច្ចកាលទៅណាមកណាជាមួយដៃគូការងារនៅតំបន់មានគ្រោះថ្នាក់ខ្ពស់

ក្រុមមួយធ្វើការសិក្សាទៅលើនារីរកស៊ីផ្លូវភេទជនជាតិនេប៉ាល់នៅប្រជុំជនផ្ទះបនក្នុងក្រុងគុលកាតា ប្រកាន់ខ្ជាប់នូវពិធីការសម្រាប់ព្រឹត្តិការណ៍មិនល្អ ជាអាទិ៍ធ្វើការជាក្រុម កាន់ទូរស័ព្ទដៃ ប្រើប្រាស់អ្នកសិក្សាស្រាវជ្រាវប្រកបដោយវិជ្ជាជីវៈ និងបទពិសោធន៍ និងមានការទទួលការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល។

ជាឧទាហរណ៍នោះបញ្ហាមធ្យោបាយធ្វើដំណើរបានបង្កឱ្យក្រុមការងារមួយដែលមានស្ត្រីពីររូបបែកគ្នាដើម្បីធ្វើការប្រមាណជា ៣០នាទី។ ស្ត្រីម្នាក់បានចូលទៅក្នុងផ្ទះបនមួយដើម្បីធ្វើការសម្ភាសន៍។ គាត់ត្រូវគេចាប់បង្ខាំងទុក។ ក្នុងប្រសាសន៍របស់ប្រធានក្រុមអ្នកធ្វើការសិក្សាស្រាវជ្រាវ ចន ហ្វ្រេដិរីក របស់អង្គការពន្លឺនៃក្តីសង្ឃឹមថា ៖

*"យើងជួបប្រទះពេលវេលាដ៏ច្របូកច្របល់មួយក្នុងការជួយសង្គ្រោះនាងត្រឡប់មកវិញ (ដោយមានការជួយអន្តរាគមន៍ពីអ្នកលេងប្រចាំទីកន្លែងនោះផង)។ នេះគឺជាការភ្លាំងភ្លាត់តែបន្តិចសោះចូលទៅក្នុងកន្លែងមួយដែលមានប្រព័ន្ធការពារតឹងរឹង ហើយបុគ្គលិករបស់យើងផ្ទាល់ហៀបនឹងធ្លាក់ខ្លួនចូលទៅក្នុងគ្រោះថ្នាក់នៃអំពើជួញដូរ។ ដូច្នេះហើយ មានស្ថានភាពខ្លះដែលតម្រូវឱ្យយើងដឹងជាមុនថា ការងារទៅធ្វើរួមគ្នាជារឿងមិនអាចចៀសវាងបាន។ ហើយជាបទពិសោធន៍បង្ហាញថា ទោះជាការត្រៀមរៀបចំជាមុនក៏ដោយ គឺយើងមិនអាចធានាថា យើងមានសុវត្ថិភាព ១០០ ភាគរយទេ"*

# ៣-　សុំការអនុញ្ញាតិ ដោយគ្មានការបង្ខិតបង្ខំ

**អ្នកធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីត្រូវតែធ្វេជាមួយបុគ្គលដែលយល់ព្រមដើម្បីចូលរួមបន្ទាប់ពីដឹងច្បាស់ពីគ្រោះថ្នាក់ដែលអាចកើតមាន និងផលប្រយោជន៍ក្នុងការចូលរួមរបស់គេ។**

ក្នុងការធ្វើកម្មវិធីនេះជាការពិបាកព្រោះការធ្វើអន្តរាគមន៍អាចបន្តរយៈពេលវែងហើយគ្រោះថ្នាក់ និងការយកចិត្តទុកដាក់អាចមានការប្រែប្រួលក្នុងកាលវេលាណាមួយ។ ក្នុងអំឡុងពេលធ្វើការសិក្សាស្រាវជ្រាវ និងធ្វើកម្មវិធីវាជាទំនួលខុសត្រូវប្រកបដោយក្រមសីលធម៌ដើម្បី :

***ជម្រាបជូនដល់ អ្នកចូលរួម និងអ្នកទទួលផលឱ្យដឹងថា :***

- គោលបំណងនៃការធ្វើសម្ភាសន៍ឬការធ្វើអន្តរាគមន៍។
- នរណាខ្លះនឹងសម្ភាសន៍ពួកគេ ឬផ្តល់ការជួយធ្វើអន្តរាគមន៍ដល់ពួកគេ និងនរណាជាអ្នកសង្កេត។
- ពិភាក្សាលើប្រធានបទ និងខ្លឹមសារកម្មវិធី។
- សក្តានុពលនៃភាពងាយទទួលរងគ្រោះថ្នាក់ និងគុណប្រយោជន៍នៃការចូលរួម។
- តើការរក្សាការសម្ងាត់ធ្វើដោយរបៀបណា។ បើគេមិនមែនជាជនរងគ្រោះ តើរបៀបនេះខ្ញុំកំពុងប្រើនេះ ធ្វើឱ្យគេរងគ្រោះថ្នាក់មែនទេ?

- សិទ្ធិរបស់ពួកគេក្នុងការសាកសួររាល់ចម្ងល់ដែលពួកគេមាន នៅពេលណាក៏បាន។
- សិទ្ធិរបស់ពួកគេក្នុងការមិនឆ្លើយឬបញ្ឈប់ការធ្វើកិច្ចសម្ភាសន៍ឬចេញពីកម្មវិធីនៅគ្រប់ពេលវេលា ក្នុងហេតុផលណាក៏ដោយ។
- សិទ្ធិរបស់ពួកគេមិនឱ្យថតរូប ឬមិនឱ្យធ្វើបទសម្ភាសន៍។

☑ ***ពិចារណា របៀបធ្វើការយល់ព្រមដោយមានការចូលរួមឱ្យបានច្រើន***

- មិនគ្រាន់តែប្រាប់អ្នកចូលរួមតែប៉ុណ្ណោះទេ ផ្ទុយទៅវិញចូរស្តាប់យោបល់ពួកគាត់ផង! ចូរសួរសំណួរដែលអាចឱ្យយើងយល់នូវគំនិតរបស់អ្នកចូលរួមនូវអ្វីជាភាពងាយរងគ្រោះថ្នាក់ ស្វែងយល់ថាតើទស្សនៈរបស់ពួកគាត់ពីការរក្សាអាថិកំបាំង និងការយល់ព្រម និងប្រាកដថាភ្នាក់ងារទាំងមូល និងការយល់ពីដំណើរការរបស់អ្នកចូលរួម ។

☑ ***ធានាថាគ្មានការបង្ខិតបង្ខំណាមួយធ្វើឡើងក្នុងការជ្រើសរើសអ្នកចូលរួមឡើយ***

- ត្រូវចងចាំជានិច្ចថា ឋានៈរបស់អ្នកអាចធ្វើឱ្យអ្នកឯទៀតខ្លាចមិនហ៊ានប្រកែក ជាពិសេសក្នុងភាពហ៊ឺហា និងអំណាចខ្ពស់អាចធ្វើឱ្យប្រជាជនមិនបានយល់ពីសិទ្ធិរបស់គេឬធ្វើឱ្យគេពិបាកបដិសេធន៍។
- ប្រសិនបើមានថវិកាត្រូវផ្តល់ជូននោះ ចំនួនទឹកប្រាក់ត្រូវមានសមភាពជាមួយការចំណាយសងគាត់សម្រាប់លះបង់ពេលវេលាក្នុងការរកទទួលទាន និង/ឬចំណាយក្នុងការធ្វើដំណើរដើម្បីឱ្យសម្ភាសន៍ចូលរួមក្នុងកម្មវិធី។

- **ប្រាក់ច្រើនក៏អាចជាកត្តាបង្កដែរ!** ការប្រើឱ្យថវិកាច្រើនក្នុងការធ្វើសម្ភាសន៍ឬក្នុងកម្មវិធីអាចបង្កការលំបាក មួយចំនួន ឧទាហរណ៍ ៖

  ១- វាធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ថាជាប់ជំពាក់ដល់រូបអ្នកដោយប្រការមិនសមរម្យ។

  ២- វាធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ថាគេត្រូវតែធ្វើអ្វីមួយដើម្បីឱ្យរឿងរ៉ាវរបស់គេទទួលបានការយកចិត្តទុកដាក់ ឬផ្តល់អ្វីដែលគេគិតថាអ្នកចង់បានសម្រាប់កម្មវិធីនោះ។

  ៣- វាក៏ធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ពិបាកដែលអាចបង្កគ្រោះថ្នាក់សម្រាប់ពួកគាត់ទៅវិញ។

  ៤- វាក៏អាចធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ថាគាត់ត្រូវតែពិភាក្សាលើរឿងដែលមានចំណុចរសើប សញ្ចេតនា ឬលើបញ្ហារបួសផ្លូវចិត្តជាដើម ដែលពួកគេពុំបានត្រៀមខ្លួនដើម្បីពិភាក្សា ហើយអ្នកក៏ពុំមែនជាអ្នកបច្ចេកទេសគ្រប់គ្រាន់ក្នុងការដោះស្រាយវានៅឡើយដែរ។

  ៥- វិជាចំនួនទឹកប្រាក់ច្រើនជាងការរំពឹងទុករបស់មន្ត្រីប្រចាំទីកន្លែងនោះ និងសមាជិកសហគមន៍នៃដៃគូអភិវឌ្ឍឯទៀត កំពុងធ្វើការសិក្សាស្រាវជ្រាវ និងធ្វើកម្មវិធីក្នុងតំបន់នោះដែរ។

- ជំនួសការឱ្យប្រាក់តែមួយមុខ អ្នកគួរតែគិតលើអំណោយមួយចំនួនដែលមិនមែនជាប្រាក់ (ចូរគិតឱ្យសមតាមភេទ និងអាយុ) ឧទាហរណ៍ ៖

  ១. តើអ្នកចូលរួមនោះស្នាក់នៅឆ្ងាយពីផ្សារដែរឬទេ? ចូរគិតពីសម្ភារមួយចំនួនដែលអាចប្រើប្រាស់ជាប្រចាំតែវាពិបាកក្នុងការជញ្ជូន មានដូចជារបស់ធ្ងន់ ឬរបស់របរជាម្ហូបអាហារ។

២. តើអ្នកចូលរួមមួយចំនួនមានកូនតូចៗដែរឬទេ? ចូរគិតពីអាហារសម្រាប់កូនក្មេង សម្ភារៈបន្ថែម សម្ភារៈលេង ឬសម្ភារៈមួយចំនួនទៀតដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ទារកទាំងនោះ។

៣. តើមានរបស់អ្វីសម្រាប់សហគមន៍ដែលអ្នកអាចចូលរួមចំណែកផ្តល់ឱ្យជាជាងឱ្យទៅតែបុគ្គលផ្ទាល់ដែរឬទេ? វាអាស្រ័យទៅលើរចនាសម្ព័ន្ធអភិបាលកិច្ចសង្គម-នយោបាយ ការចូលរួមចំណែកទាំងនេះរួមមាន ការផ្តល់ទៅឱ្យមេភូមិដើម្បីបែងចែកបន្តទៅកាន់សមាជិកក្នុងភូមិរបស់គាត់ ការទៅឱ្យក្រុមស្ត្រីដែលធ្វើការសហការជាមួយឬបែងចែកទៅកាន់ក្រុមក្នុងឃុំ ឬជាមូលនិធិជាដើម។

*មើលឧបសម្ព័ន្ធ A1 – ទម្រង់ពិនិត្យមើលឡើងវិញអំពីក្រមសីលធម៌ ក្នុងការសិក្សាស្រាវជ្រាវក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សរបស់ UNIAP* ឧទាហរណ៍ ទម្រង់មួយសម្រាប់អ្នកសិក្សាស្រាវជ្រាវធ្វើឱ្យធានាចំពោះការពិនិត្យមើលលើក្រមសីលធម៌វិធីសាស្ត្រស្រាវជ្រាវរបស់ពួកគេ។

*មើលឧបសម្ព័ន្ធ A2 – ប័ណ្ណបញ្ជាក់ពីការយល់ព្រមក្នុងការចូលរួម* ឧទាហរណ៍នៃរបៀបដើម្បីបញ្ចូលការយល់ព្រមផ្ទាល់មាត់ទៅក្នុងវិក័យប័ត្របង់ប្រាក់ជាលាយលក្ខអក្សរ។

*មើលឧបសម្ព័ន្ធ A3 – គោលការណ៍ណែនាំ ចំពោះការធ្វើជាសាក្សីពីការយល់ព្រមផ្ទាល់មាត់* និងប្រអប់អត្ថបទដែលរាប់ទាំងការយល់ព្រមដែលមិនលាយលក្ខអក្សរ។



ក្រុមការងារ UNIAP ប្រទេសឡាវ និងមគ្គុទេសក៏ជនជាតិមង ដើរទៅកាន់ភូមិដាច់ស្រយ៉ាលមួយ ដោយត្រូវចំណាយពេលបីម៉ោងពីផ្លូវធំជាមួយទឹកដោះគោ និងអាហារកំប៉ុងធុនៗសម្រាប់ជារង្វាន់ក្នុងការចូលរួម។

## ការយល់ព្រមជាលាយលក្ខអក្សរ និងដោយផ្ទាល់មាត់

**ណាមួយត្រឹមត្រូវជាង និងក្នុងស្ថានភាពបែបណា?**

អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអនុវត្តកម្មវិធីត្រូវប្រមូលយកហត្ថលេខាដើម្បីបញ្ជាក់ពីការយល់ព្រមដោយផ្ទាល់មាត់ ក្នុងការយល់ព្រមចូលរួមនេះ។ ការយល់ព្រមដោយផ្ទាល់មាត់រវាងអ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តកម្មវិធីជាមួយអ្នកចូលរួម ជាប្រការល្អមួយ និងគួរតែបន្តប្រើប្រាស់សម្រាប់សហគមន៍ ដែលជាអ្នកមិនចេះអក្សរ។ នៅពេលដែលមានការប្រើប្រាស់ សំណៅជាលាយលក្ខអក្សរនិងចុះហត្ថលេខាអាចធ្វើឱ្យអ្នកទាំងនេះមានការភ័យខ្លាច និងអាចបង្កអសន្តសុខជាងការការពារពួកគេ។ **សំណួរចំនួន៥ដើម្បីសុំការយល់ព្រមដោយផ្ទាល់មាត់**ត្រូវបានណែនាំឱ្យប្រើប្រាស់ ដោយមានសាក្សីដឹងឮហើយចុះហត្ថលេខា ប្រសិនណាបើទទួលបានចម្លើយវិជ្ជមានពីសំណួរទាំង៥នោះ :

\+ + +

១- តើអ្នកមានការព្រួយបារម្ភក្នុងការធ្វើបទសម្ភាសន៍ជាមួយខ្ញុំដែរឬទេ?

២- តើអ្នកត្រូវការពិភាក្សាជាមួយនរណាម្នាក់មុនពេលឱ្យខ្ញុំសម្ភាសន៍ដែរឬទេ? (ពិនិត្យមើលភាពភ័យខ្លាចរបស់គេចំពោះអ្នកដទៃ)

៣- តើខ្ញុំអាចសម្ភាសន៍នៅពេលនេះ និងទីកន្លែងនេះបានដែរឬទេ? (ធានាឱ្យមានភាពសមរម្យ ភាពងាយស្រួល និងសន្តិសុខ ដោយរាប់បញ្ចូលទាំងការមិនលួចស្តាប់ពីសំណាក់អ្នកឯទៀត)

៤- តើអ្នកមានសំណួរអ្វីដើម្បីសួរខ្ញុំអំពីការធ្វើបទសម្ភាសន៍នេះដែរឬទេ? (ធានាថាមិនមានសេចក្តីត្រូវការ ឬសំណួរដែលមិនទាន់ដោះស្រាយ)

៥- តើខ្ញុំអាចធ្វើការសម្ភាសន៍បានដែរឬទេ? (ការយល់ព្រមនៅខាងក្រោយគេ)

\+ + +

# ជនរងគ្រោះដោយអំពើជួញដូរ ការផ្សព្វផ្សាយជាសាធារណៈ និងការយល់ព្រម

## វត្តមានរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

### តើអ្វីខ្លះជាការទទួលយកបានចំពោះវត្តមានរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងការសិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស?

ការសម្ភាសន៍ជនរងគ្រោះដោយការកេងប្រវ័ញ្ច និងជនរងគ្រោះឯទៀតនោះគួរតែមានឱកាសដើម្បីសម្រេចចិត្ត ថាតើគេចង់ឱ្យយើងសម្ភាសន៍ ថតរូប ឬធ្វើការសាកសួរពីសំណាក់សារព័ត៌មានដែរឬទេ។

គោលបំណងរបស់សារព័ត៌មានគួរតែត្រូវពន្យល់ឱ្យបានច្បាស់លាស់។ ភាពរងាយរងគ្រោះថ្នាក់ចម្បង និងផលវិបាកដែលពាក់ព័ន្ធក្នុងការផ្សព្វផ្សាយជាសាធារណត្រូវពិនិត្តមើល និងពិភាក្សា។ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នផ្សេងៗទៀតគួរតែទទួការយល់ដឹងផងដែរ។ ក្នុងករណីខ្លះទៀត ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងច្បាប់ការពារជនរងគ្រោះដោយអំពើនេះ អាចដាក់ពិន័យដល់បុគ្គលណាម្នាក់ដែលបង្ហាញអត្តសញ្ញាណរបស់ជនរងគ្រោះ។

តាមការពន្យល់ខាងលើវាច្បាស់ណាស់ថាតម្លៃក្នុងការជម្រាបជូនពីវត្តមានរបស់អ្នកសារព័ត៌មានត្រូវធ្វើឡើងដល់គ្រប់ភាគីទាំងអស់ (រួមទាំងជនរងគ្រោះ) មុនពេលព្រឹត្តិការណ៍កើតឡើង តែការអនុវត្តហាក់បីដូចជាមិនត្រូវបានគោរពឱ្យបានខ្ជាប់ខ្ជួនឡើយ។

តាមគោលការណ៍ច្បាប់អ្នកសារព័ត៌មានមិនគួរមានវត្តមានក្នុងប្រតិបត្តិការបោសសម្អាត និងសង្គ្រោះ ឬការធ្វើមាតុភូមិនិវត្តន៍ និងការជួយជ្រោមជ្រែងដើម្បីឱ្យវិលត្រឡប់មកវិញ។

## ការថតរូប និងថតវីឌីអូជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអ្នកដទៃដែលពាក់ព័ន្ធ

### តើបម្រាមអ្វីខ្លះគួរតែយកចិត្តទុកដាក់មុនពេលថតរូប ថតសម្លេង ឬថតវីឌីអូជនរងគ្រោះ ឬអ្នកពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស?

ទីមួយ ត្រូវទទួលការយល់ព្រមជាមុនសិនមុនពេលថតរូប ថតវីដេអូ ឬថតសម្លេងអ្នកពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជនរងគ្រោះ បុគ្គលងាយរងគ្រោះ អ្នកឆ្លើយតបនឹងអំពើនេះ ឬភ្នាក់ងារឯទៀត។

ទីពីរ ការកំណត់អត្តសញ្ញាណជនរងគ្រោះគួរតែត្រូវរក្សាជាការសម្ងាត់ក្នុងកំណត់ហេតុ រូបថត ឬវីដេអូដែលប្រើជាសាធារណៈ (ដូចជាលើរបាយការណ៍ ឬលើគេហទំព័រ) តាមរយៈការបិទបាំងអត្តសញ្ញាណ ជាពិសេសមុខ។

ទីបី ការបដិសេធន៍ និងឈ្មោះមិនពិតគួរតែប្រើដើម្បីការពារអត្តសញ្ញាណរបស់ជនរងគ្រោះ និងគួរបញ្ជាក់ឱ្យបានច្បាស់លាស់នូវ បុគ្គលទាំងឡាយណាដែលមុខមាត់របស់គេមិនបានបិទបាំងនេះ។ ឧទាហរណ៍រូបថតរបស់បុគ្គលដែលគេដាក់បង្ហាញក្នុងរបាយការណ៍ ឬគេហទំព័រប្រឆាំងនឹងអំពើជួញដូរមនុស្ស គេនឹងអាចសន្មតដោយមិនត្រឹមត្រូវថាគាត់ជាជនរងគ្រោះ ឬឧក្រិដ្ឋជនក្នុងអំពើនេះ។ ហេតុដូច្នេះហើយ អ្នកប្រើ (disclaimer) ដើម្បីបញ្ជាក់ចំពោះបញ្ហានេះ ។

ផ្ទុយទៅវិញបណ្ឌិត ដើរីដ ហ្វាញហ្គោល ផលិតករភាពយន្ត និងជាអ្នកប្រតិបត្តិក្នុងកម្មវិធីប្រឆាំងនឹងអំពើជួញដូរមនុស្ស បានកត់សម្គាល់ថាសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរដែលជាមនុស្សពេញវ័យនឹងរៀបរាប់រឿងរ៉ាវរបស់គេប្រសិនបើគេស្ម័គ្រ: *"ក្នុងខណៈដែលអត្តសញ្ញាណរបស់ជនរងគ្រោះគួរតែការពារនោះ មនុស្សពេញវ័យមានសិទ្ធិដើម្បីរៀបរាប់រឿងរ៉ាវរបស់ខ្លួនដោយប្រសិនបើគេចង់ និងត្រូវបានពន្យល់។"*

# ៤- ធានាចំពោះការរក្សាអនាមិកភាព និងរាល់អាថ៌កំបាំងឱ្យអស់ពីលទ្ធភាព

**អ្នកធ្វើការសិក្សាស្រាវជ្រាវ និងអ្នករៀបចំកម្មវិធីគួរតែធានារក្សាភាពអាថ៌កំបាំង និងអនាមិកភាពអស់ពីលទ្ធភាព និងគួរតែពិភាក្សាឱ្យបានច្បាស់លាស់លើបញ្ហានេះជាមួយអ្នកចូលរួម។**

ការការពារអត្តសញ្ញាណ និងចម្លើយរបស់អ្នកចូលរួមតែងតែចារឿងសំខាន់ណាស់ដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់ពួកគេ។ ក្នុងពេលជាមួយគ្នានេះដែរមានកាតព្វកិច្ចមួយចំនួនអាចកើតមានឡើង ហើយទោះជាអ្នកសិក្សាស្រាវជ្រាវដែលមានបទពិសោធន៍ខ្ពស់ និងមានឆន្ទៈល្អអាចជួបប្រទះជាមួយអាចប្រឈមមុខជាមួយបញ្ហាក្រមសីលធម៌ដែរឧទាហរណ៍ ការទម្លាយព័ត៌មានពីអ្នកចូលរួមក្នុងកម្មវិធី ប្រភពសិក្សាស្រាវជ្រាវ និង/ឬកងកម្លាំងនគរបាល។

ជាទូទៅ ការរក្សាភាពសម្ងាត់គួរតែត្រូវបានគេការពារ ប៉ុន្តែក្នុងកាលៈទេសៈណាមួយដែលបង្កឱ្យមានការផ្សព្វផ្សាយនោះអ្នកអនុវត្តកម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សអាចប្រឹក្សាជាមួយឯកសារវិជ្ជាជីវៈលើក្រមសីលធម៌ខាងក្រោមនេះ ៖

- ក្រមសីលធម៌របស់សមាគមនរវិទ្យាអាមេរិកាំង (១៩៩៨)[៥]
- វិធានក្រមសីលធម៌នៃចិត្តវិទូ និងក្រមវជ្ជប្បវេណី(២០០២) របស់សមាគមចិត្តសាស្ត្ររបស់អាមេរិកាំង[៦]
- ក្រមសីលធម៌នៃសមាគមនសង្គមវិទ្យា (១៩៩៧)[៧]
- គោលការណ៍ណែនាំក្រមសីលធម៌សម្រាប់ការអនុវត្តល្អប្រសើររបស់អ្នកស្រាវជ្រាវ សមាគមសង្គមនរវិទ្យារបស់ចក្រភពអង់គ្លេស និងខាំមិនវែល [៨]
- វិធានក្រមសីលធម៌សម្រាប់អ្នកសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធជាមួយមនុស្ស(២០០៥) សេចក្តីថ្លែងការណ៍គោលនយោបាយរបស់ក្រុមប្រឹក្សាទាំងបី នៃរដ្ឋាភិបាលកាណាដា [៩] និង
- សេចក្តីថ្លែងការជាតិស្តីអំពី វិធានក្រមសីលធម៌សម្រាប់អ្នកសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធជាមួយមនុស្ស (២០០៧) ក្រុមប្រឹក្សាសិក្សាស្រាវជ្រា អូស្ត្រាលី និងក្រុមប្រឹក្សាសិក្សាស្រាវជ្រាវវេជ្ជសាស្ត្រ និងសុខភាពជាតិ។[១០]

ដើម្បីធានាការរក្សាការសម្ងាត់របស់អ្នកចូលរួម ចូរពិនិត្យមើលកំណត់ត្រាកិច្ចសម្ភាសន៍ឧបករណ៍សិក្សាស្រាវជ្រាវ អ្នកផ្តល់បទសម្ភាសន៍និងបញ្ជីអ្នកចូលរួមក្នុងកម្មវិធី និងរបៀបពិភាក្សាករណីជាមួយអ្នកដទៃទៀតដូចខាងក្រោម ៖

[5] http://www.aaanet.org/committees/ethics/ ethcode.htm
[6] http://www.apa.org/ethics/code2002.pdf
[7] http://www.asanet.org/galleries/default-file/Code%20of%20Ethics.pdf
[8] http://www.theasa.org/ethics/guidelines.htm
[9] http://pre.ethics.gc.ca/english/pdf/ TCPS%20October%202005_E.pdf
[10] http://www.nhmrc.gov.au/publications/ synopses/ e35syn.htm

☑ *ធានាថាអ្នកចូលរួមយល់នូវអ្វីគេអាចសង្ឃឹមចំពោះការថែរក្សាការសម្ងាត់ និងអនាមិកភាពចាប់តាំងពីការចាប់ផ្តើមកិច្ចសម្ភាសន៍និងការធ្វើកម្មវិធី។*

- ពន្យល់ឱ្យបានច្បាស់លាស់ប្រកបដោយពាក្យសមរម្យ។ សម្រាប់ការសិក្សាស្រាវជ្រាវវិញ ជនរងគ្រោះគួរយល់ឱ្យច្បាស់ថាគ្មាននរណាម្នាក់អាចដឹងពីចម្លើយទេ ហើយគ្មាននរណាម្នាក់មានសិទ្ធិមកអានឯកសារ និងមើល ឈ្មោះដែលភ្ជាប់ជាមួយនោះទេ។ សម្រាប់ធ្វើកម្មវិធី ត្រូវរក្សាអនាមិកភាពក្នុងរយៈពេលមួយ ដោយធ្វើការផ្តល់សេវាតាមរយៈ ទូរស័ព្ទ ឬនៅក្នុងការិយាល័យជាជាងនៅផ្ទះ ឬក្នុងសហគមន៍របស់គេ។

☑ *ចៀសវាងសរសេរព័ត៌មានអំពីអត្តសញ្ញាណទាំងស្រុង (នាមខ្លួន ឈ្មោះរបស់ឪពុកម្តាយ កន្លែងកំណើត រូបថត ។ល ។) ទៅលើទំព័រតែមួយរបស់ចម្លើយ។*

- ប្រើលេខកូដប្រសិនបើចាំបាច់ ប្រើសន្លឹកមួយផ្សេងទៀតដើម្បីសរសេរឈ្មោះដោយភ្ជាប់ជាមួយលេខកូដនេះផង។ ឬប្រើឈ្មោះប្រឌិតឱ្យថ្មី។ ប្រសិនបើមិនចាំបាច់នោះមិនត្រូវសរសេរឈ្មោះទាំងស្រុងទេ។

☑ *ចៀសវាងធ្វើការពិភាក្សាករណីបុគ្គលណាម្នាក់ជាមួយអ្នកឯទៀតទេ ទោះជាមន្ត្រីក្នុងភូមិ ប្រធានភូមិ អាជ្ញាធរដែលដី ឬអ្នកឯទៀតដែលគ្មានពាក់ព័ន្ធនឹងការងាររក្សាអាថ៌កំបាំងទេនោះ។*

- ជាការប្រសើរនិយាយរឿងទូទៅតែប៉ុណ្ណោះ ដូចជាក្នុងករណីរឿងរ៉ាវកើតឡើងក្នុងសហគមន៍ទាំងមូល។

☑ ***ផ្លាស់ប្តូរ**ព័ត៌មានពីស្ថានរបស់បុគ្គល និងលក្ខណអត្តសញ្ញាណក្នុងការធ្វើបទបង្ហាញជាសាធារណៈ ចំពោះនរណាអាចជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។*

- នេះរាប់បញ្ចូលឈ្មោះទាំងអស់នៅក្នុងព័ត៌មានសម្ភាសន៍និងសម្គាល់ (ជាពិសេសភ្នែក) និងទីកន្លែង (ដូចជាអ្វីសម្រាប់សម្គាល់ទីកន្លែង និងផ្លាកសញ្ញា) ដែលបង្ហាញពីលក្ខណៈនៅក្នុងរូបថត។



Two examples of appropriately altered identifying characteristics. Note that facial expressions are still apparent.

## ការអនុវត្តល្អក្នុងប្រទេសកម្ពុជា ៖ ការចែករំលែកបទពិសោធន៍ពីជនរងគ្រោះដោយអំពើជួញដូរជាសាធារណៈ

នៅពេលដែលមានការអញ្ជើញជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬជនរងគ្រោះដោយការកេងប្រវ័ញ្ចពលកម្មដើម្បីចែករំលែកបទពិសោធន៍របស់គាត់ក្នុងកិច្ចប្រជុំ ឬសិក្ខាសាលាក្រុមការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរបានផ្តល់លទ្ធភាពដល់ជនរងគ្រោះអង្គុយនៅក្នុងបន្ទប់ ឬនៅក្រោយរបាំងឡប់ឡៅដើម្បីលាក់បាំងអត្តសញ្ញាណរបស់ពួកគាត់។ ហើយអ្វីដែលអ្នកស្តាប់បានដឹងនោះគឺត្រឹមតែសម្លេងប៉ុណ្ណោះ។

## ការអនុវត្តល្អក្នុងប្រទេសភូមា ៖ ការជួយដល់អ្នកធ្វើមាតុភូមិនិវត្តន៍

អង្គការក្រៅរដ្ឋាភិបាលមួយក្នុងប្រទេសភូមាបានផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់អ្នកធ្វើមាតុភូមិនិវត្តន៍ដែលជាជនរងគ្រោះដោយអំពើជួញដូរ និងជនរងគ្រោះដោយអំពើដទៃទៀតបានដឹងថានៅពេលដែលក្រុមការងារទៅមើលដល់ផ្ទះដើម្បីតាមដាននោះជាហេតុធ្វើឱ្យមានសហគមន៍ខ្លះនៅក្បែរនោះបានសន្មតថា អ្នកដែលគេចូលទៅដល់ផ្ទះ សុទ្ធតែជាជនរងគ្រោះដោយអំពើជួញដូរ។ អ្នកទទួលផលពីកម្មវិធីបានសំណូមពរមិនឱ្យក្រុមការងាររបស់អង្គការទៅដល់ផ្ទះទៀតព្រោះថាវាអាចអាប់ឱនកិត្តយសសម្រាប់ពួកគេ។ ដើម្បីឆ្លើយតបនឹងសំណូមពរនេះអង្គការបានធ្វើការកែប្រែតវិយាបទដោយផ្តល់សេវាជួយឧបត្ថម្ភដល់អ្នកទទួលផលពីកម្មវិធីតាមរយៈទូរស័ព្ទ និងធ្វើការណាត់ជួបនៅឯការិយាល័យអង្គការជំនួសវិញ។

## ការអនុវត្តល្អក្នុងប្រទេសថៃ៖ ការដាក់ឈ្មោះប្រឌិតឱ្យ

អ្នកធ្វើការសិក្សាស្រាវជ្រាវសម្រាប់វិស័យអប់រំនៅសកលវិទ្យាល័យ ជុឡាឡុងកន ធ្វើការសម្ភាសន៍អ្នករងគ្រោះដោយអំពើជួញដូរមនុស្សបានធ្វើសំណូមពរទៅកាន់អ្នកផ្តល់បទសម្ភាសន៍ជ្រើសរើសយកឈ្មោះដោយខ្លួនឯងតាមចិត្តចង់ ជាធម្មតាពួកគេបានជ្រើសរើសយកឈ្មោះតារាល្បីៗ។ លើសពីនេះទៀតឈ្មោះដែលទើបដាក់ថ្មីនេះក៏ជាឱកាសសម្រាប់អ្នកសម្ភាសន៍ធ្វើឱ្យបរិយាកាសក្នុងកិច្ចសន្ទនាកាន់តែមានភាពរីករាយ ហើយវាក៏អាចកសាងការទុកចិត្តគ្នាផងដែរ។

**ការអនុវត្តល្អក្នុងខេត្តអាងយ៉ាង ប្រទេសវៀតណាមៈ**
**ការសិក្សាស្រាវជ្រាវថ្នាក់មូលដ្ឋានទាក់ទិនទៅនឹងរបាយការណ៍បទឧក្រិដ្ឋដែលអាចកើតមាន**

សម្ព័ន្ធភាពអាងយ៉ាង ដុងថាប់ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស (ADAPT) បានរៀបចំធ្វើការសិក្សាស្រាជ្រាវមួយដល់មូលដ្ឋានក្នុងខេត្តអាងយ៉ាង ប្រទេសវៀតណាម ដើម្បីធ្វើការប៉ាន់ប្រមាណលើអំពើជួញដូរមនុស្សដែលកើតមានឡើងក្នុងខេត្តនេះ។ វិធីសាស្ត្រមានទាំងការធ្វើការស្រាវជ្រាវសមាជិកមូលដ្ឋានតាមតំបន់ចំណុចក្តៅ សមាជិកអាចពាក់ព័ន្ធ ឬមិនពាក់ព័ន្ធទៅនឹង ជនរងគ្រោះ និងឧក្រិដ្ឋជននៃអំពើជួញដូរមនុស្ស។

ហេតុដូច្នេះហើយ ADAPT ត្រូវតែរៀបចំរបាយការណ៍ដែលអាចចោទប្រកាន់ជនឧក្រិដ្ឋបាន។ ទីមួយ កត់សម្គាល់ថាពួកគេនឹងធ្វើការសម្ភាសន៍បុគ្គលណាដែលអាចប្រាប់នូវរាល់ព័ត៌មានដែលឈានទៅជាភស្តុតាងសម្រាប់បទល្មើសមួយ ឬបង្ហាញភាពជាប់ទាក់ទងរបស់គេទៅនឹងអំពើល្មើស។ ពួកគេក៏បានយល់ព្រមជាពាក្យសម្តីដោយចំហរជាមួយអ្នកសម្ភាសន៍ថា ប្រសិនបើមានករណីខ្លះជាករណីអំពើជួញដូរមនុស្សដែលអ្នកចូលរួមនោះមានបំណងឱ្យ (ADAPT) ធ្វើការរាយការណ៍ទៅអាជ្ញាធរដោយអនាមិក នោះគាត់ត្រូវតែផ្តល់ការអនុញ្ញាតឱ្យ ADAPT ក្នុងការរាយការណ៍។

ទីពីរ ប្រសិនបើមានករណីត្រូវរាយការណ៍រឿងទាំងនោះត្រូវបានរៀបចំបន្ទាប់ពីការសិក្សាស្រាវជ្រាវចប់ចំនួនបីខែ ហើយទម្រង់នៃការសិក្សាស្រាវជ្រាវមិនត្រូវបានផ្តល់ឱ្យទៅនគរបាលដែរ។ ការបង្កើតឱ្យមានទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដីត្រូវធ្វើមុនពេលចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវ ហើយរាល់ទម្រង់ឯកសារបានត្រូវរក្សាជាអនាមិក (គ្មានព័ត៌មានពីទីកន្លែង ឬអាស័យដ្ឋាន) ដើម្បីរក្សាអាថ៌កំបាំងដូចអ្វីដែលបានសន្យា។

លីលីផាន ប្រធានក្រុមសិក្សាស្រាវជ្រាវបានមានប្រសាសន៍ថា ៖

*“ចំពោះពួកយើង ការការពារអត្តសញ្ញាណរបស់អ្នកផ្តល់សម្ភាសន៍មានសារៈសំខាន់ណាស់។ ព្រោះវាជាមូលដ្ឋានក្នុងការទុកចិត្តគ្នា ដែលយើងអាចទទួលបានព័ត៌មានទាំងអស់ពីពួកគាត់។”*

# ៥- រៀបចំអ្នកបកប្រែភាសា និងក្រុមការងារឱ្យបានគ្រប់គ្រាន់

**ពិនិត្យឡើងវិញនូវឧបសម្ពន្ធ ៨ ប្រការគួរ និងមិនគួរគប្បីធ្វើនៅពេលបំពេញភារកិច្ចរបស់ UNIAP ហើយបន្ទាប់មក:**

- ☑ ធានាឱ្យបានថាអ្នកបកប្រែនិង បុគ្គលិកចុះទៅបំពេញការងារទាំងអស់បានទទួលការណែនាំនិងបង្ហាត់បង្រៀន ឱ្យប្រតិបត្តិតាមគោលការណ៍ទាំងអស់នោះ សម្រាប់ការធ្វើសម្ភាសន៍និងការអនុវត្តកម្មវិធី។
- ☑ ពិនិត្យឡើងវិញនូវគោលការណ៍ជាមួយសមាជិកក្នុងក្រុមទាំងមូល ហើយពិភាក្សាជាមួយអ្នកចុះបំពេញការងារថាតើគោលការណ៍នោះពាក់ពន្ធ័យ៉ាងដូចម្តេចទៅនឹងស្ថានភាពជាក់ស្តែងដែលក្រុមការងាររបស់អ្នកនឹងចុះទៅធ្វើការងារនោះ។
- ☑ ពិភាក្សាឱ្យបានច្បាស់លាស់ពីពាក្យពេចន៍ដែលត្រូវប្រើទាក់ទិននឹងបច្ចេកទេស និង/ឬប្រធានបទដែលជាចំណុចរសើប ហើយថាត្រូវប្រើភាសាណាមួយដែលសមរម្យនោះអង់គ្លេស ឬភាសាតាមតំបន់នោះ។
- ☑ គិតគូរពីការរៀបចំរបៀបអង្គុយសម្រាប់អ្នកត្រូវសម្ភាសន៍ ឬអ្នកចូលរួម ដែលមានអ្នកសម្ភាសន៍សំខាន់ អ្នកបកប្រែ អ្នកកត់ត្រា អ្នកសម្ភាសន៍បន្ទាប់បន្សំ និងអ្នកផ្សេងទៀតដែលពាក់ពន្ធ័ (មិនគួរមានមនុស្សច្រើន អង្គុយនៅជុំវិញអ្នកផ្តល់សម្ភាសន៍ឡើយ)។
- ☑ អាហារសម្រន់ ភេសជ្ជៈ ឧបករណ៍លេងសម្រាប់ក្មេងៗ និង ឧបករណ៍ផ្សេងទៀត : ទិញនិងត្រៀមរៀបចំឱ្យបានស្រេចបាច់ជាមុន។

☑ ប្រសិនបើអ្នកសង្កេតកិច្ចសម្ភាសន៍មានវត្តមាន (ពេលខ្លះវាមិនអាចចៀសវាងបាន ដូចជាសាច់ញាតិ ឬ ភ្នាក់ងាររដ្ឋាភិបាល) ចាំបាច់ត្រូវពិភាក្សាបញ្ហាសំខាន់ៗដែលអាចប្រឈមមុខ និងរិះរកវិធានការដោះស្រាយនៅក្នុងក្រុមការងារឱ្យបានរួចរាល់ជាមុនសិន។

☑ ពិនិត្យមើលពីហេតុដែលអាចបង្កគ្រោះថ្នាក់ និងឧបសគ្គផ្សេងៗ។ ចំណាយពេលសង្កេតដោយប្រុងប្រយ័ត្នបង្ហាត់បង្រៀន និងធ្វើការសាកល្បងរាល់អ្នកបកប្រែ និងសមាជិកក្រុមការងារដែលចុះមូលដ្ឋានទាំងអស់ ដើម្បីធានាថាពួកគេអាចឆ្លើយតប ទៅនឹងស្ថានភាពបន្ទាន់នានាដែលអាចកើតឡើង។

☑ បង្កើតរបៀបប្រើក្រសែភ្នែក និងរបៀបផ្តល់សញ្ញាឱ្យគ្នាទៅវិញទៅមកក្នុងការសម្ភាសន៍ដែលមានអ្នកសួរច្រើននាក់ ធ្វើដូច្នេះដើម្បីឱ្យអ្នកបកប្រែអាចនៅតែបកប្រែបានប្រសើរ និងអ្នកសួរអាចរក្សាការសួរសំណួរបានល្អ។ ធានាឱ្យបានថាអ្នកសម្ភាសន៍និងអ្នកបកប្រែ រក្សាអារម្មណ៍និងទឹកមុខស្មើ ផ្តោតទៅលើប្រធានបទ ហើយកុំនិយាយលើសពីការចាំបាច់។ ធានាឱ្យបានថាសមាជិកនៅក្នុងក្រុមចេះរបៀបផ្តល់សញ្ញាឱ្យគ្នានៅពេលដែលមានបញ្ហាបន្ទាន់។



បុគ្គលិក UNIAP និង UNDP នៅប្រទេសភូមា ពិនិត្យមើលឡើងវិញនូវវិធីសាស្រ្ត និងបញ្ហាដែលអាចកើតឡើងផ្សេងៗ (រូបខាងឆ្វេង) មុនពេលធ្វើការសម្ភាសន៍នៅភូមិគោលដៅ(រូបខាងស្តាំ)។

ចូរពិនិត្យរូបភាពខាងក្រោម និង ធ្វើឱ្យប្រាកដថាក្រុមរបស់អ្នកពិចារណាឱ្យបានល្អិតល្អន់នូវការរៀបចំអង្គុយ និងភាសា កាយវិការ រួមមាន អ្នកសួរចម្លង អ្នកសួរបន្ទាប់បន្សំ អ្នកកត់ត្រា អ្នកបកប្រែ និងអ្នកថតរូប។

**កិច្ចពិភាក្សាក្រុមចំណាប់អារម្មណ៍តូច**



- អ្នកសម្ភាសន៍ចម្បង (ស្ត្រីពេញវ័យនៅខាងស្តាំដៃបង្អស់) កំពុងអង្គុយស្មើជាមួយអ្នក ចូលរួម (ក្មេងស្រីទាំង៤នៅខាងឆ្វេងដៃ) ហើយអង្គុយជិតក្មេងទាំងនោះ។
- អ្នកសម្ភាសន៍រក្សាក្រសែភ្នែកយ៉ាងល្អជាមួយអ្នកចូលរួមដោយរួសរាយរាក់ទាក់ និងទឹកមុខយកចិត្តទុកដាក់ប៉ុន្តែ មិនលម្អៀង និងកាយវិការសមរម្យទៅកាន់កុមារីទាំងនោះ។
- អ្នកបកប្រែកំពុងអង្គុយនៅខាងឆ្វេងជាប់នឹងអ្នកសម្ភាសន៍ (មិននៅក្នុងរូបថតនេះទេ) ធ្វើដូចនេះកុមារីទាំងអស់ អាច មើលទាំងអ្នកសម្ភាសន៍ និងអ្នកបកប្រែក្នុងទិសដៅតែមួយ។

**ការហ្វឹកហាត់ទៅលើនៅក្នុងក្រុមពិភាក្សាដែលមានភាពស្មុគស្មាញមួយ**



- អ្នកសម្របសម្រួលក្នុងការហ្វឹកហាត់នោះ (ស្ត្រី៨រូបឈរនៅក្បែរតុ) មានចំនួនគ្រប់គ្រាន់ដើម្បីធានាថាអ្នកចូលរួម យល់ច្បាស់ពីរបៀបអនុវត្តលំហាត់លើក្រដាសនេះ (រូបបុរសទាំង៥នាក់) ហើយម្នាក់ៗឆ្លើយតាមគំនិត និងការយល់ឃើញរបស់គាត់ម្នាក់ៗ។
- មានអ្នកចាំកត់ត្រាឈរនៅម្ខាង (ស្ត្រីនៅខាងស្តាំ) នូវដំណើរការនេះ។ ធ្វើដូចនេះអ្នកសម្របសម្រួលអាចផ្តោតការយកចិត្តទុកដាក់ទៅលើអ្នកចូលរួមដោយគ្មានទើសទែង។



Photo credits: Lisha Li

## ការពិភាក្សាជាក្រុមតូច១ជាមួយអ្នកសង្កេត

- ការសម្ភាសន៍ជាក្រុមតូចនេះធ្វើឡើងនៅភូមិតូចមួយនៅក្នុងរដូវកាលសម្រាកពីការងារ។ ដូច្នេះមានមនុស្សជាច្រើននាក់មកឈរមើលការសម្ភាសន៍ក្នុងក្រុមតូចមួយនេះ ប៉ុន្តែអ្នកទាំងនោះមិនពាក់ពន្ធ័នឹងការសម្ភាសន៍ទាល់តែសោះ។ នេះជារឿងដែលអ្នកធ្វើសម្ភាសន៍ជួបប្រទះដោយចៀសមិនផុត។
- ក្រុមការងារសម្រេចកាត់បន្ថយការពិភាក្សាទៅលើបញ្ហារសើបមួយចំនួន និងបានអង្គុយព័ទ្ធជុំវិញដើម្បីពិភាក្សា។ អ្នកទទួលការធ្វើសម្ភាសន៍អង្គុយនៅកណ្តាល (បុរសពាក់អាវពណ៌ក្រម៉ៅ និងបុរសដែលមានបង់កក្រម៉ា នៅក្នុងរូបថតពង្រីក) ហើយអ្នកសម្ភាសន៍សំខាន់ម្នាក់អង្គុយនៅចន្លោះអ្នកទាំងពីរ (បុរសនៅចុងខាងស្តាំ នៅក្នុងរូបពង្រីក)។ អ្នកសម្ភាសន៍ឯទៀត និងអ្នកកត់ត្រា (មនុស្ស៤នាក់ដែល នៅខាងឆ្វេងបង្អស់ នៅក្នុងរូបពង្រីក) អង្គុយបាំងអ្នកឱ្យគេសម្ភាសន៍ពីអ្នកឈរមើល។

## កិច្ចពិភាក្សា : ចំពោះការសិក្សាស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល

**ទំនាក់ទំនង និងគុណភាព**

តើណាមួយគួរតែធ្វើការស្រាវជ្រាវទៅលើការប្រឆាំងអំពើជួញដូរមនុស្ស: អ្នកដែលមានទំនាក់ទំនងទៅដល់សហគមន៍ ឬអ្នក ដែលបានទទួលការបណ្តុះបណ្តាលពីការស្រាវជ្រាវ?

បញ្ហាថាតើនរណាគួរតែធ្វើការស្រាវជ្រាវទៅលើការជួញដូរមនុស្ស ជាចំណោទដ៏ក្តៅគគុករយៈពេលជាយូរឆ្នាំ ហើយវាក៏ជាប្រធានបទនៃការពិភាក្សា នៅពេលធ្វើពង្រាងគោលការណ៍ណែនាំនេះដែរ។

ជាទូទៅការជ្រើសរើសមានលក្ខណៈចែកដាច់ស្រឡះពីគ្នា : ជំរើសទី១ គឺអ្នកជំនាញដែលទទួលការបណ្តុះបណ្តាលជំនាញយ៉ាងជាក់លាក់ និងជាអ្នកប្រឹក្សាយោបល់ឯករាជ្យ ឬជាអ្នកបានឆ្លងកាត់ការបង្ហាត់បង្ហាញពីរបៀបប្រមូលទិន្នន័យទាំង តាមបរិមាណ និងគុណភាព ព្រមទាំងជំនាញខាងវិភាគដែលចាំបាច់សម្រាប់គាត់តែង និងធ្វើការសិក្សាស្រាវជ្រាវផ្នែកប្រឆាំងអំពើជួញដូរមនុស្ស។ អ្នកស្រាវជ្រាវដែលបានទទួលការអប់រំ ជាទូទៅក៏មានបទពិសោធន៍ផ្នែកក្រមសីលធម៌ និង ការពិនិត្យទៅលើការសិក្សាទៅលើមនុស្សផងដែរ។

ផ្ទុយទៅវិញអង្គការមិនមែនរដ្ឋាភិបាលមានវត្តមានហើយអាចចុះទៅដល់ប្រជាជនក្នុងមូលដ្ឋាន ប៉ុន្តែបុគ្គលិកទាំងនោះពុំបានទទួលការបណ្តុះបណ្តាលក្នុងការធ្វើការស្រាវជ្រាវឱ្យស៊ីជម្រៅដោយប្រើប្រាស់សំណាកជាប្រព័ន្ធ និងទម្រង់ប្រកបដោយវិភាគសម្រាប់ការទាញយកលទ្ធផល និងការធ្វើសេចក្តីសន្និដ្ឋានលើរបកគំហើញពីការស្រាវជ្រាវនោះ។ អង្គការក្រៅរដ្ឋាភិបាល ក៏ខ្វះខាតបទពិសោធន៍ចំពោះក្រមសីលធម៌ ការរក្សាទិន្នន័យឱ្យបានល្អ ការធ្វើតេស្តសាកល្បង ការកែលំអ ការរៀបចំឯកសារ និងវិធីសាស្ត្រដែលបានអនុវត្តដើម្បីប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវក្នុងពេលបន្ទាប់ទៀត។

ដោយសារថា  អង្គការមិនមែនរដ្ឋាភិបាលមានការខ្វាយខ្វល់ជាខ្លាំងក្នុងការអនុវត្តកម្មវិធីប្រឆាំងការជួញដូរមនុស្សនៅទូទាំងពិភពលោក  អង្គការទាំងនោះពេលខ្លះត្រូវបានគេសន្មតថាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការស្រាវជ្រាវ  ផ្នែកជួញដូរមនុស្សគ្រប់ប្រភេទ  ទោះបីជាពួកគេខ្វះជំនាញផ្នែកបច្ចេកទេសក៏ដោយ។  ការសន្មតបែបនេះនាំឱ្យមានការផ្តួចផ្តើមធ្វើការស្រាវជ្រាវថ្មីមួយដែលពុំបានប្រតិបត្តិតាមក្រមសីលធម៌    ហើយការវិភាគទៅលើស្ថានភាពជាក់ស្តែងតិចតួចមិនសមស្របសម្រាប់ជាព័ត៌មានដើម្បីបង្កើតកម្មវិធី  ឬរៀបចំគោលនយោបាយថ្នាក់ជាតិ  ឬថ្នាក់ខ្ពស់ជាងនេះបានឡើយ។

តើនេះមានន័យថាយើងត្រូវការអ្នកស្រាវជ្រាវ  និងអ្នកពិគ្រោះយោបល់  ដែលបានទទួលការបណ្តុះបណ្តាលជ្រៅជ្រះលើផ្នែកប្រឆាំងការជួញដូរមនុស្សមែនទេ?  ទោះជាទទួលបានការបណ្តុះបណ្តាលជ្រៅជ្រះក៏ដោយក៏មិនធានាបានថាទេពកោសល្យ  និងពុទ្ធិផ្នែកសីលធម៌ដែលចាំបាច់សម្រាប់ធ្វើការសិក្សាស្រាវនោះសុទ្ធតែបានជោគជ័យទាំងអស់ដែរ។  ផ្ទុយទៅវិញបើមានចំណេះដឹងសមស្របហើយបែរជាគ្មានទំនាក់ទំនងល្អ  និងការយល់ដឹងអំពីប្រជាជនទេ  នោះការចូលទៅធ្វើការសិក្សាស្រាវជ្រាវក្នុងសហគមន៍ក៏មិនអាចទទួលបានព័ត៌មានប្រកបដោយផ្លែផ្កាព្រោះថាខ្វះការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ  និងខ្វះការយល់ដឹងពីទីតាំងភូមិសាស្ត្រផងដែរ។

ក្នុងរយៈពេល១០ឆ្នាំចុងក្រោយមកនេះ   ចំនួននៃការស្រាវជ្រាវបែបប្រព័ន្ធ   ដែលអាចយកជាគំរូបាននៅក្នុងផ្នែកជួញដូរមនុស្សបានកើនឡើង  ប៉ុន្តែការសិក្សាដែលផ្អែកទៅលើវិធីសាស្ត្រលំអិតនិងដែលបានកែលំអ  នៅមានចំនួនតិចតួច។  ក្រៅពីនេះទិន្នន័យ    និងស្ថិតិអំពីអំពើជួញដូរនៅមានភាពទន់ខ្សោយហើយមានប្រទេសតែមួយចំនួនតូចប៉ុណ្ណោះបានផ្សព្វផ្សាយនូវទិន្នន័យថ្នាក់ជាតិ   និងទិន្នន័យពីការវិវឌ្ឍពីអំពើជួញដូរមនុស្សដែលអាចទុកចិត្តបាន   ហើយមានអំណះអំណាងគ្រប់គ្រាន់។   ទោះជាយ៉ាងណាក៏ដោយ   បញ្ហាទាំងអស់នេះត្រូវតែធ្វើការកែតម្រូវ   និងជំហានបន្ទាប់ទៀតប្រហែលជាត្រូវចាប់យកជំរើសថ្មីៗ  ដូចជាក្រុមស្រាវជ្រាវរួមគ្នារវាងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល   និងអ្នកទទួលការបណ្តុះបណ្តាលពីសាលា   ការកសាងសមត្ថភាពនៃសម្រាប់ធ្វើការសិក្សាស្រាវជ្រាវដល់បុគ្គលិកអង្គការ   និងជនរងគ្រោះដោយអំពើជួញដូរ    ការឧបត្ថម្ភគាំទ្រទៅដល់ការសិក្សារយៈពេលវែងលើការប្រឆាំងអំពើជួញដូរ   ដើម្បីអាចឱ្យក្រុមអ្នកសិក្សាបង្កើតទំនាក់ទំនងជិតស្និទ  និងយូរអង្វែង   ជាមួយសហគមន៍ដែលមានបញ្ហានេះ  ប្រធានសហគមន៍  និងអង្គការជាច្រើនទៀត។

# ៦- រៀបចំព័ត៌មានបញ្ជូនទាំងឡាយ និងត្រៀមខ្លួនជាស្រេចចំពោះរាល់ការធ្វើអន្តរាគមន៍

## ត្រៀមខ្លួនជាស្រេចសម្រាប់ស្ថានភាពដែលអាចកើតឡើងទាំង ៨ ដូចខាងក្រោម និង ស្ថានភាពផ្សេងទៀត

ពិគ្រោះយោបល់ជាមួយអ្នកអនុវត្តកិច្ចការប្រឆាំងអំពើជួញដូរ និងសមាជិកសហគមដើម្បីប្រមូលព័ត៌មានសមស្រប និងដឹងពីរបៀបដើម្បីត្រៀមខ្លួនឱ្យបានល្អសម្រាប់ស្ថានភាពបន្ទាន់មួយចំនួន ដូចជាប្រសិនបើអ្នកចូលរួម:

### ១ មើលទៅឈឺ ឬមានការបំពានលើរាងកាយ

តាមរយៈការសាកសួរ អ្នកត្រូវបាកដក្នុងចិត្តថាជនរងគ្រោះកំពុងត្រូវការជំនួយផ្នែកសុខភាពដែរឬយ៉ាងណា។ ប្រសិនបើគាត់បដិសេធ ប៉ុន្តែបើរាងកាយគាត់បង្ហាញច្បាស់ថាគាត់ចាំបាច់ត្រូវការសេវានោះ (ដូចជាគ្រុន តក់ស្លុត ច្របូកច្របល់ មានស្នាមជាំ ។ល។) យើងគប្បីរកគ្រូពេទ្យជាបន្ទាន់។ ជនរងគ្រោះប្រហែលជាចង់គេចវេសពីបុគ្គលិកពេទ្យ អាចមកពីការខ្មាស់អៀន ខ្លាចការព្យាបាល (ដូចជាខ្លាចម្ជុល) មិនចង់មានទំនាក់ទំនងជាមួយអ្នកផ្សេងក្រៅពីអ្នកដែលជួយគាត់ ឬខ្លាចថាប្រសិនបើគេរកឃើញ និងកត់ត្រាថាមានការរំលោភបំពាននោះ ជនផ្សេងទៀតដែលមានការពាក់ព័ន្ធនឹងមានបញ្ហានៅពេលក្រោយ។

## ២ បង្ហាញរោគសញ្ញាទុក្ខព្រួយខ្លាំង

អ្នកអាចឃើញពីស្ថានភាពមិនប្រក្រតីនៃសតិអារម្មណ៍របស់ជនរងគ្រោះតាមរយៈការសួរសំនួរ និងការសន្ទនា។ សញ្ញាមួយចំនួនដូចជា ច្របូកច្របល់ វង្វេងវង្វាន់ ភ័យខ្លាច អស់សង្ឃឹម ឆាប់ខឹង អាចពិនិត្យមើលដឹងដោយងាយស្រួល។ ស្ថានភាពសតិអារម្មណ៍របស់ជនរងគ្រោះអាចបណ្តាលមកពីការទទួលរងការរំលោភបំពានខ្លាំង តានតឹងក្នុងចិត្ត អស់សង្ឃឹម ភ័យខ្លាចមានការសងសឹក និង/ឬការបំពារបំពានលើរូបរាងកាយ។ ស្ថិតក្នុងស្ថានភាពបែបនេះយើងគួរតែព្យាយាមស្វែងរកសេវាសុខភាពផ្លូវចិត្តពីគ្រូពេទ្យឯកទេស។ មុនពេលធ្វើសម្ភាសន៍ត្រូវរកដំណោះស្រាយ និងត្រៀមខ្លួនសម្រាប់ស្ថានការណ៍បែបនេះឱ្យស្រេចទុកជាមុន។

## ៣ សុំឱ្យគាត់ទូរស័ព្ទទៅគ្រួសារគាត់ ឬសុំទូរស័ព្ទផ្តល់ជាដំណឹងទៅកាន់ក្រុមគ្រួសាររបស់គាត់

ព្យាយាមធ្វើតាមសំណូមពរនេះតាមលទ្ធភាពរបស់អ្នក។ ត្រូវមានទូរស័ព្ទចល័តជាប់ខ្លួនជានិច្ចជាការប្រសើរ។ មុនពេលចុចទូរសព្ទ័ត្រូវសួរបញ្ជាក់ឱ្យបានច្បាស់លាស់ពីអ្វីដែលជនរងគ្រោះចង់ប្រាប់ទៅគ្រួសារគាត់។ ការបញ្ជាក់ឡើងវិញនេះក្នុង គោលបំណងដើម្បីចៀសវាងការភ្លេច ឬបាត់ព័ត៌មានដែលគាត់ចង់ប្រាប់ទៅគ្រួសារគាត់ដោយសារតែការនិយាយក្នុងពេលដ៏ខ្លីនេះ។វាកាន់តែប្រសើរបើជនរងគ្រោះទូរស័ព្ទទៅក្រុមគ្រួសាររបស់គាត់ដោយខ្លួនឯង។

**៤ សុំឱ្យអ្នកជួយជូនត្រលប់ទៅផ្ទះ សុំឱ្យអ្នកយកគាត់ទៅជាមួយដែរ ប្រាប់អ្នកថា គាត់មានអារម្មណ៍ដូចជាគ្មានសុវត្ថិភាព ឬសន្តិសុខគ្រប់គ្រាន់ ឬមិនមានកន្លែងសុវត្ថិភាពសម្រាប់សម្រាកឡើយ**

មុនពេលធ្វើការសម្ភាសន៍ ពិភាក្សាដើម្បីរកដំណោះស្រាយក្នុងករណីសំណើរដូចខាងលើនឹងត្រូវលើកឡើង។ ចាត់ទុកថាសំណើរប្រភេទនេះមានសារៈសំខាន់ និង ត្រូវចាត់វិធានការជាបន្ទាន់។ វិធានការនោះអាចតាមរយៈការជួយពីអជ្ញាធរមូលដ្ឋាន ឬអង្គការមិនមែនរដ្ឋាភិបាល/អង្គការសហគមន៍ដែលបានជ្រើសរើស។ កំណត់គោលដៅទុកជាមុនថាតើភ្នាក់ងារ ឬអង្គការណាមួយដែលអាចមានលទ្ធភាពឆ្លើយតបនូវសេចក្តីត្រូវការនោះ។

**៥ ប្រាប់អ្នកថាពួកគាត់ត្រូវការបួងសួង ប៉ុន្តែគាត់មិនទទួលបានការអនុញ្ញាតឱ្យប្រតិបត្តិសាសនារបស់ពួកគាត់នៅទីនេះទេ**

ប្រសិនជាមានសំណើរបែបនេះ ត្រូវកំណត់ថាតើហេតុអ្វីការបួងសួងតាមបែបសាសនារបស់គាត់មិនមានការអនុញ្ញាតិឱ្យធ្វើតាមប្រពៃណីគាត់។ ផ្អែកទៅលើហេតុផល ចូរស្វែងរកដំណោះស្រាយដែលគោរពសិទ្ធិក្នុងការប្រតិបត្តិជំនឿ សាសនារបស់គាត់។ ត្រូវមានព័ត៌មានពាក់ព័ន្ធតាមខ្លួនជានិច្ច។

**៦ ស្នើរសុំអាហារ ឬប្រាក់ ឬ ប្រាក់សម្រាប់ទិញអាហារឱ្យទារករបស់គាត់**

ប្រសិនបើមានតម្រូវការម្ហូបអាហារសម្រាប់អ្នកចូលរួម និង/ឬទារករបស់គាត់ អាហារគួរតែផ្តល់ឱ្យតាមសំណូមពរ។ ជាធម្មតា ទោះក្នុងស្ថានភាពបែបណាក៏ដោយវាងាយស្រួលក្នុងការរកអាហារ ហើយការសម្ភាសន៍ត្រូវធ្វើក្រោយពេលទទួលទានអាហាររួច។ ប្រសិនបើមានការស្នើសុំជាប្រាក់ ត្រូវសំរេចចិត្តដោយផ្អែកទៅតាមថ្លៃសំណងដែលបានព្រមព្រៀង គ្នាពីមុនពេលធ្វើសម្ភាសន៍។

**៧ ប្រាប់អ្នកថាគាត់ត្រូវបានជួយសង្គ្រោះនៅប្រតិបត្តិការបង្ក្រាប ឬពីដំបូងត្រូវចាប់ខ្លួនដោយបង្ខំឱ្យទុកកូនចោល ឱ្យចាកចេញពីផ្ទះដោយមិនបានបិទទ្វារ ឱ្យទុករបស់មានតម្លៃ ឬឯកសារចោល ។ល។**

ព្យាយាមជួយគាត់តាមលទ្ធភាពអាចធ្វើទៅបាន។ ជាដំបូងនិយាយជាមួយបុគ្គលិកមណ្ឌលផ្តល់ទីជម្រក ឬអជ្ញាធរនៅកន្លែងដែលគេឃាត់ខ្លួនគាត់ដើម្បីរិះរកមធ្យោបាយដែលអាចដោះស្រាយបញ្ហាខាងលើ។ ពិនិត្យមើលទៅតាមស្ថានភាពជាក់ស្តែង និងជួយឱ្យពួកគាត់ធ្វើការទាក់ទងជាមួយសមាជិកគ្រួសារ ឬ អ្នកជិតខាងដែលទុកចិត្តបានណាម្នាក់ឱ្យជួយមើលថែរក្សាទារក ឬ ទ្រព្យសម្បត្តិរបស់គាត់។

**៨ និយាយថាគាត់ត្រូវបានគេ វាយដំ រំលោភ ឬបំពារបំពានណាមួយ ដោយនគរបាល បុគ្គលិកមណ្ឌលផ្តល់ទីជម្រក ថៅកែរបស់ពួកគាត់ ឬអជ្ញាធរដទៃទៀត ឬត្រូវឆែកឆេរដោយបង្ខំ ឬពិនិត្យរកមើលមេរោគអេដស៍ដោយគ្មានការស្ម័គ្រចិត្ត**

សេចក្តីលម្អិតរាល់ការរំលោភបំពានទាំងនេះគួរតែកត់ត្រាទុក។ ពីគ្រោះយោបល់ជាមួយជនរងគ្រោះថាតើគាត់ចង់ធ្វើយ៉ាងដូចម្តេចចំពោះរឿងនោះ (ចង់ប្តឹង ឬមិនប្តឹងទេ) មិនត្រូវលើកពីភាពជោគជ័យក្នុងការប្តឹងផ្តល់ដែលធ្វើឱ្យគាត់រំពឹងទុកពីជ័យជំនះក្នុងរឿងក្តីរបស់គាត់ពេកទេ ប៉ុន្តែត្រូវគោរពតាមឆន្ទៈរបស់គាត់ជានិច្ច។ មុននឹងចែករំលែកព័ត៌មានទៅឱ្យអាជ្ញាធរមូលដ្ឋានក្រោមការយល់ព្រមពីជនរងគ្រោះ ត្រូវពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានដែលគួរឱ្យទុកចិត្តបំផុតដើម្បីកំណត់ជ្រើសរើសភ្នាក់ងារសមស្របណាមួយដើម្បីរាយការណ៍ពីអំពើហឹង្សានោះ។ ភ្នាក់ងារនោះអាចជានគរបាលមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើផ្នែករំលោភសិទ្ធិមនុស្ស ឬអាចជានាយកដ្ឋានជាតិ ឬភ្នាក់ងារដែលដោះស្រាយរឿងក្តីប្រឆាំងនឹងនគរបាល។ ការសម្រេចចិត្តគួរតែធ្វើឡើងដោយផ្អែកទៅតាមបរិបទតាមតំបន់ ឧទាហរណ៍ តើធ្លាប់មានប្រវត្តពីអំពើពុករលួយ ការប្រើប្រាស់អំណាចដើម្បីបំពានការគំរាមកំហែង ឬមានការសងសឹក បន្ទាប់ពីអ្នកធ្វើសម្ភាសន៍បានចាកចេញទៅ។

## សូមត្រៀមខ្លួនចំពោះស្ថានភាពបន្ទាន់ ដែលអាចជួបប្រទះក្នុងការធ្វើកម្មវិធី និងការសិក្សាស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស

១ ធ្វើទស្សនកិច្ចដើម្បីត្រួតពិនិត្យកម្មវិធី ឬទៅធ្វើការសិក្សាស្រាវជ្រាវទៅកាន់កម្មវិធីការពារជនរងគ្រោះមានដូចជា (ជម្រក កម្មវិធីបណ្តុះបណ្តាលដើម្បីផ្លាស់ប្តូរជីវភាព) អាចជួបប្រទះនូវស្ថានភាពបន្ទាន់មួយចំនួន។ ត្រូវតែត្រៀមខ្លួនសម្រាប់ឆ្លើយតបទៅនឹងការខ្វះខាតសម្ភារៈ និងសេវាក្នុងទីជម្រក និងព្យាយាមរកទីកន្លែងស្ងាត់កំបាំងសមល្មមដើម្បីធ្វើការសន្ទនាជាមួយជនរងគ្រោះមួយចំនួនឱ្យផុតពីក្រសែភ្នែករបស់អ្នកគ្រប់គ្រង ឬអាជ្ញាធរ។ អ្នករងគ្រោះដោយអំពើជួញដូរមនុស្សក៏ត្រូវការទទួលយកកម្មវិធីបណ្តុះបណ្តាលដើម្បីកែប្រែជីវភាពរបស់ខ្លួនមុនពេលដែលពួកគាត់ត្រូវបានគេអនុញ្ញាតឱ្យចេញទៅធ្វើការខាងក្រៅ។ ត្រូវតាមឃ្លាំមើលពីសញ្ញាជម្ងឺផ្លូវចិត្តរបស់គាត់។

២ កិច្ចសម្ភាសន៍នៅក្នុងពន្ធនាគារជាមួយអ្នកជួញដូរមនុស្សអាចរកឃើញថាអ្នកដែលត្រូវគេជួញដូរនៅទីណា អ្នកទទួលកំហុសជំនួសគេ ឬ អ្នកគ្មានកំហុស អាចត្រូវឃុំឃាំងដោយសារអំពើពុករលួយ ឬដោយសារការអនុវត្តប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌនៅ មានកម្រិត។ ត្រូវត្រៀមខ្លួនកត់ត្រា និងដើម្បីដោះស្រាយនូវរាល់ករណីបែបនេះ។

៣ តាមពិនិត្យសង្កេតតាមដានក្រោយពេលបញ្ជូនត្រលប់ទៅកាន់គេហដ្ឋានវិញ ឬក្រោយពេលអន្តរាគមន៍ អាចរកឃើញថាជីវិតរបស់ជនរងគ្រោះនៅតែប្រឈមមុខនឹងបញ្ហា និង ការគំរាមកំហែងរបៀបណា។ ត្រៀមខ្លួនដើម្បីដោះស្រាយសំណូមពរឱ្យជួយចំពោះការខ្មាស់អៀន ភាពអត់ការងារធ្វើ ការខ្វះខាតប្រាក់កាស បំណុល បញ្ហាសតិអារម្មណ៍ បញ្ហាក្នុងគ្រួសារ ឬបញ្ហាអាពាហ៍ពិពាហ៍ ឬបញ្ហាដទៃទៀតដែលអាចជាប់ទាក់ទិននឹងការទទួលជំនួយនោះ។

៤ ការទៅធ្វើទស្សនកិច្ចនៅសហគមន៍ (ប្រភព ឬគោលដៅ) ដោយក្រុមការងារធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដែលគេស្គាល់នោះ អាចបន្សល់ទុកនូវបញ្ហាដូចជាការខ្មាស់អៀន ការគុំគួន ឬ ឥទ្ធិពលអវិជ្ជមានផ្សេងទៀត។ កាត់បន្ថយបញ្ហាទាំងអស់នេះតាមរយៈការរក្សាភាពធម្មតាជាមួយអ្នកដឹកនាំសហគមន៍ និងសមាជិក ចំពោះដំណើរទស្សនកិច្ចឱ្យសមស្របតាមដែលអាច។ បង្កើតមធ្យោបាយក្នុងការពិនិត្យមើលលើបញ្ហានេះ ដោយវិធីចុះទៅទីកន្លែងដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទសួរ។

# ៧- មិនត្រូវស្ងាត់ស្ងៀមក្នុងការជួយអ្នកឯទៀតៈចូររៀបចំព័ត៌មានរបស់អ្នកសម្រាប់ប្រើប្រាស់ឱ្យមានប្រយោជន៍និងត្រឹមត្រូវ

**តើអ្វីទៅជារឿងល្អបំផុតដែលទទួលបានពីកម្មវិធី ឬការស្រាវជ្រាវ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សរបស់អ្នក?**

**សម្រាប់ការសិក្សាស្រាវជ្រាវ សូមពិនិត្យមើល...**

- ☑ ជូនដំណឹងទៅកាន់អ្នកចូលរួមពីលទ្ធផលដែលទទួលបាន និងអ្វីដែលត្រូវធ្វើក្នុងពេលបន្តទៀត។
- ☑ ផ្តល់អនុសាសន៍ដល់ របកគំហើញរបស់អ្នកឱ្យបានច្បាស់លាស់ និងងាយៗ ដើម្បីបង្កភាពងាយស្រួលចំពោះដៃគូរក្នុងការកែលម្អអន្តរាគមន៍ របស់គេ ពីបទពិសោធន៍ដែលបានរកឃើញ។
- ☑ ធ្វើការបណ្តុះបណ្តាលដល់អ្នកសិក្សាស្រាវជ្រាវក្នុងមូលដ្ឋាន ស្ថាប័នអប់រំសិក្សា និងអង្គការក្រៅរដ្ឋាភិបាល នូវជំនាញ និងវិធីសាស្ត្រវិភាគរបស់អ្នក ដើម្បីឱ្យពួកគាត់អាចបន្ត និង/ឬពង្រីកឱ្យបានស៊ីជម្រៅជាងមុនប្រកបដោយក្រមសីលធម៌សមស្របមួយ។
- ☑ ធ្វើការបោះពុម្ពសម្រាប់ចែកផ្សាយ និងធ្វើបទបង្ហាញពីលទ្ធផល នៃការសិក្សាស្រាវជ្រាវ ឱ្យបានទូលំទូលាយទៅដល់វេទិកាជាតិ និងអន្តរជាតិផងដែរ។

*សម្រាប់កម្មវិធី សូមពិចារណា...*

☑ ធ្វើការវាយតម្លៃដោយត្រឹមត្រូវ និងឯករាជ្យ និងវិភាគពីផលប៉ះពាល់ ព្រមទាំងចែករំលែកនូវបទពិសោធន៍ល្អ និងបទពិសោធន៍មិនល្អជាមួយដៃគូរអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ និងរដ្ឋាភិបាលឱ្យបានទូលំទូលាយ។

☑ សុំឱ្យអ្នកចូលរួម និងអ្នកដែលទទួលផលពីកម្មវិធី វាយតម្លៃលើប្រសិទ្ធភាពនៃកម្មវិធី និងស្នើរសុំយោបល់របស់ពួកគេលើចំណុចខ្វះខាតដើម្បីកែលម្អ។

☑ យកបទពិសោធន៍ល្អៗដើម្បីអនុវត្តន៍ជាបន្តទៀត ហើយធ្វើការកែសម្រួល ឬលះបង់ចំណុចអវិជ្ជមានទាំងឡាយចោល។



China Government delegation discusses the results of an anthropologist's recent research findings regarding child sex tourism in Asia.

ប្រតិភូរដ្ឋាភិបាលចិនពិភាក្សាពីលទ្ធផលនៃរបកគំហើញថ្មីផ្នែកនរវិទ្យាដែលទាក់ទងទៅនឹងការធ្វើទេសចរណ៍ដើម្បីមករួមភេទជាមួយកុមារនៅទ្វីបអាស៊ី។

# ឧបសម្ព័ន្ធ

## ឧបករណ៍សម្រាប់ប្រើប្រាស់ប្រកបដោយក្រមសីលធម៌ក្នុងការធ្វើកម្មវិធី និងការសិក្សាស្រាវជ្រាវ ដើម្បីប្រឆាំងអំពើជួញដូរ

## គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស
## ដំណាក់កាលទី បី: ២០០៧-២០១០

## ទម្រង់ពិនិត្យលើក្រមសីលធម៌

## សម្រាប់ការសិក្សាស្រាវជ្រាវដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

*ការណែនាំសម្រាប់ក្រុមអ្នកធ្វើការសិក្សាស្រាវជ្រាវរបស់ UNIAP*

១ ពិនិត្យឡើងវិញដោយយកចិត្តទុកដាក់ នូវគោលការណ៍ណែនាំឆ្នាំ២០០៨ របស់ UNIAP ស្តីពី ក្រមសីលធម៌ និងសិទ្ធិមនុស្សនៅក្នុងការប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្តោតសំខាន់ទៅលើគោលការណ៍ណែនាំទាំង៧របស់ UNIAP។

២ ពិនិត្យឡើងវិញពីវិធីសាស្រ្តរបស់ខ្លួនផ្ទាល់ ហើយឆ្លុះបញ្ចាំងលើសន្តិសុខ និងលើក្រមសីលធម៌ និងមានសារសំខាន់ក្នុងការសិក្សាស្រាវជ្រាវនោះ។

៣ បំពេញទម្រង់នេះ ហើយបញ្ជូនទៅឱ្យ UNIAP តាមពេលកំណត់ បានសរសេរនៅក្នុងលិខិតអមដែលភ្ជាប់មក ជាមួយគោលការណ៍ណែនាំនេះ ដោយសរសេរក្នុងចន្លោះ <u>និងភ្ជាប់ជាមួយនូវឯកសារដែលចាំបាច់ដូចជា:</u> លិខិតយល់ព្រមជាភាសាអង់គ្លេស និងភាសាក្នុងតំបន់នោះ(សំនួរទី៣)។

៤ ឆ្លើយសំណួរផ្សេងៗទៀតរបស់ UNIAP ដែលសង្កត់ធ្ងន់ទៅលើផ្នែកក្រមសីលធម៌។

*សូមថ្លែងអំណរគុណជាអនេកពីក្រុមការងាររបស់ UNIAP*

## គោលការណ៍ណែនាំទី១: ជៀសវាងបង្កគ្រោះថ្នាក់: សម្តែងការអាណិតអាសូរ ប៉ុន្តែដោយមិនលម្អៀង

**សំនួរទី១:** តើមានបញ្ហាសន្តិសុខ អារម្មណ៍ ឬក៏កត្តាគ្រោះថ្នាក់ផ្សេងទៀតអ្វីខ្លះដែលអ្នកគិតថាអាចជួបប្រទះនៅពេលសម្ភាសន៍ ជាមួយជនដែលអាចជាអ្នករងគ្រោះពីអំពើជួញដូរ (ឬជនដែលពាក់ពន្ធ័នឹងអំពើជួញដូរមនុស្ស) ដែរឬទេ? សូមពិពណ៌នាពីបរិយាកាសនៃទីកន្លែងដែលអ្នកធ្វើកិច្ចសម្ភាសន៍ ពីហានីភ័យដែលបានជួប និងដំណោះស្រាយរបស់អ្នកក្នុងការកាត់បន្ថយគ្រោះថ្នាក់នោះ។

(*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*)

## គោលការណ៍ណែនាំទី២: ផ្តល់អាទិភាពចំពោះសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន: កំណត់ និងកាត់បន្ថយគ្រោះថ្នាក់

**សំនួរទី២:**សូមពណ៌នាបញ្ហាសន្តិសុខ និងគ្រោះថ្នាក់ដែលអាចជួបប្រទះ និងពីផែនការរបស់អ្នកក្នុងការកាត់បន្ថយបញ្ហាទាំងអស់នោះ។ ពណ៌នាពីការឆ្លើយតបរបស់អ្នកចំពោះស្ថានភាពសន្តិសុខក្នុងគ្រាមានអាសន្ននោះ។

(*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*)

## គោលការណ៍ណែនាំទី៣: សុំការអនុញ្ញាតិ ដោយគ្មានការបង្ខិតបង្ខំ

**សំនួរទី៣:** ពណ៌នាពីរបៀបផ្តល់ប្រាក់ឧបត្ថម្ភឱ្យដល់អ្នកត្រូវសម្ភាសន៍ ហើយនិងមូលហេតុនៃការផ្តល់ប្រាក់នោះ។ សូមភ្ជាប់ជាមួយនូវលិខិតយល់ព្រម ដោយប្រើជាភាសាអង់គ្លេស និងភាសាក្នុងស្រុក។

(*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*)

| |
|---|
| **គោលការណ៍ណែនាំទី៤: ធានាចំពោះការរក្សាអនាមិកភាព និងរាល់អាថ៌កំបាំងឱ្យអស់ពីលទ្ធភាព** |
| **សំនួរទី៤:**សូមពណ៌នាពីការធានាអះអាងពីការរក្សាការសម្ងាត់ និងអនាមិកភាពទៅឱ្យអ្នកផ្តល់សម្ភាសន៍។ សូមពិពណ៌នាពីការប្រមូលទិន្នន័យ និងប្រព័ន្ធរក្សាទិន្នន័យហើយថាតើវាអាចរក្សាដោយរបៀបណា។ |
| (*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*) |

| |
|---|
| **គោលការណ៍ណែនាំទី៥: រៀបចំអ្នកបកប្រែភាសា និងក្រុមការងារឱ្យបានគ្រប់គ្រាន់** |
| **សំនួរទី៥:** សូមពណ៌នាពីរបៀបវិនិច្ឆ័យនិងដំណើរការនៃការជ្រើសរើស ជួល ហ្វឹកហ្វឺនអ្នកបកប្រែ និងក្រុមការងារ។ ផ្តល់ព័ត៌មានលំអិតពីចំនួនមនុស្សនៅក្នុងក្រុមការងាររបស់អ្នក មុខនាទី ទំនួលខុសត្រូវ និងអាជ្ញាធរពាក់ព័ន្ធ |
| (*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*) |

**គោលការណ៍ណែនាំទី៦: រៀបចំព័ត៌មានបញ្ជូន និងត្រៀមខ្លួនជាស្រេចចំពោះរាល់ការធ្វើអន្តរាគមន៍**

**សំនួរទី៦:** *(ប្រសិនជាកំពុងសម្ភាសន៍ជនរងគ្រោះ)* តើអ្នកអាចនឹងសម្ភាសន៍ជនរងគ្រោះដែលលនូវស្ថិតក្នុងស្ថានភាព អាចមានគ្រោះថ្នាក់នៅឡើយមែនទេ? ប្រសិនជាដូច្នេះសូមពណ៌នាថាតើអ្នកធ្វើដូចម្តេចក្នុងស្ថានភាពបន្ទាន់ដូចជា មានករណីរំលោភបំពានធ្ងន់ធ្ងរ ឬជនរងគ្រោះសុំឱ្យជួយជាបន្ទាន់ ឬជួយរំដោះគាត់ចេញ។ (ប្រសិនជាសម្ភាសន៍ជាមួយសាច់ញាតិ អ្នកជិតខាង ឬជនដទៃទៀតដែលអាចពាក់ពន្ធ័នឹងជនរងគ្រោះ) តើអ្នកអាចនឹងសម្ភាសន៍ បុគ្គលនោះអាចផ្តល់ព័ត៌មានដែលអាចយកជាភស្តុតាងនៃបទឧក្រិដ្ឋ ឬដែលអាចពាក់ពន្ធ័ក្នុងបទឧក្រិដ្ឋ? ប្រសិនជាដូច្នោះ សូមពណ៌នាពីរបៀបដែលអ្នកត្រូវដោះស្រាយយ៉ាងណាជាមួយព័ត៌មានដែលទទួលបាន ប្រសិនជាប៉ូលីសចង់បានព័ត៌មាននោះពីអ្នក ឬក្រុមរបស់អ្នកដែរ។

(*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*)

**គោលការណ៍ណែនាំទី៧: ចៀសវាងការស្នាក់ស្ទើរក្នុងការជួយអ្នកឯទៀត : ចូររៀបចំព័ត៌មានរបស់អ្នកសម្រាប់ប្រើប្រាស់ឱ្យមានប្រយោជន៍និងត្រឹមត្រូវ**

**សំនួរទី៧:** សូមពណ៌នាពីផែនការដើម្បីប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់អ្នកចំពោះអ្នកទទួលផលឱ្យបានទូលំទូលាយ។

(*សរសេរចំលើយ របស់អ្នកនៅទីនេះ សរសេរតាមដែលអ្នកត្រូវការ*)

# ឧបសម្ព័ន្ធ ក២

## វិក័យបត្រិបង់ប្រាក់ដែលមានភ្ជាប់ជាមួយលិខិតយល់ព្រមធ្វើសម្ភាសន៍

ខាងក្រោមគឺជាទម្រង់គំរូដែលបញ្ចូលរួមគ្នានូវវិក័យបត្រិបង់ប្រាក់ និងលិខិតយល់ព្រមឱ្យធ្វើសម្ភាសន៍។ ធ្វើដូចនេះយើងត្រូវការលិខិត និងហត្ថលេខាតែ១ប៉ុណ្ណោះពីអ្នកចូលរួម។ ហើយហត្ថលេខានោះធានាថាអ្នកចូលរួមអាចទទួលបានប្រាក់ឧបត្ថម្ភបន្ទាប់ពីយល់ច្បាស់ និងយល់ព្រមក្នុងការផ្តល់បទសម្ភាសន៍ ឬចូលរួមក្នុងកម្មវិធី។

- ត្រូវចុះហត្ថលេខាមុនការសម្ភាសន៍ ឬកម្មវិធី។
- ប្រសិនជាអ្នកចូលរួមមិនអាចអានលិខិតនេះ ឬមានការពិបាកក្នុងការអាននោះ សូមអានឱ្យគាត់ស្តាប់ និងធ្វើតាម គោលការណ៍ណែនាំស្តីពីការយល់ព្រមដោយស្ម័គ្រចិត្តនៅចំពោះមុខសាក្សី (ឧបសម្ព័ន្ធ ក៣)
- នៅពេលដែលអ្នកចូលរួមចុះហត្ថលេខា មិនគួរមានឈ្មោះអ្នកផ្សេងទៀតឬហត្ថលេខាលើសន្លឹកនេះទៀតឡើយ ពោលគឺលិខិតយល់ព្រម១មានឈ្មោះតែមួយប៉ុណ្ណោះ។
- ត្រូវពន្យល់អ្នកចូលរួមយល់ច្បាស់ថា គាត់ត្រូវនិយាយតែរឿងមួយមុខគត់ប៉ុណ្ណោះ។ គាត់មិនចាំបាច់ប្រឌិតរឿងយកមកឱ្យជាថ្នូរនិងប្រាក់ដែលយើងនឹងផ្តល់ជូនដល់គាត់ឡើយ។

## គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

កាលបរិច្ឆេទ :

ទីកន្លែង :

ទទួលប្រាក់ចំនួន..........................[ជាតម្លៃ]សម្រាប់ពេលវេលារបស់ខ្ញុំក្នុងការផ្តល់សម្ភាសន៍ជាមួយ......................[ឈ្មោះអ្នកសម្ភាសន៍] ដែលជាបុគ្គលិករបស់......................................[ឈ្មោះស្ថាប័ន] ដែលចង់ដឹងពី...........................[គោលបំណងនៃការស្រាវជ្រាវ]។

ខ្ញុំយល់ច្បាស់ថាខ្ញុំនឹងឆ្លើយតែសំនួរណាដែលខ្ញុំចង់ឆ្លើយ។ ខ្ញុំគ្រាន់តែត្រូវឆ្លើយសំនួរដោយស្មោះត្រង់ហើយប្រសិនបើខ្ញុំមិនចង់ឆ្លើយសំនួរណាមួយ ឬបញ្ឈប់ការសម្ភាសន៍ខ្ញុំនឹងប្រាប់ទៅអ្នកសម្ភាសន៍។ ប្រសិនជាខ្ញុំមានសំនួរ ឬបញ្ហាណាមួយអំពីការសម្ភាសន៍នេះ ខ្ញុំនឹងទាក់ទងអ្នកសម្ភាសន៍តាមរយៈ.................................[ព័ត៌មានទំនាក់ទំនងរបស់អ្នកសម្ភាសន៍]។

ឈ្មោះ

ហត្ថលេខា ឬស្នាមមេដៃ

# ឧបសម្ព័ន្ធ ក៣

## គោលការណ៍ណែនាំស្តីពីការយល់ព្រមផ្ទាល់មាត់ ដោយស្ម័គ្រចិត្តនៅចំពោះមុខសាក្សី

**គោលបំណង:**

គោលបំណងនៃនិតិវិធីគោលការណ៍ណែនាំស្តីពីការយល់ព្រមផ្ទាល់មាត់ដោយស្ម័គ្រចិត្តនៅចំពោះមុខសាក្សី គឺដើម្បីធានាឱ្យបានថាអ្នកឆ្លើយសំនួរ (ដែលអាច មិនចេះអក្សរ ភ័យខ្លាច ជ្រួលច្របល់ក្នុងចិត្ត ឬស្ថិតក្នុងសម្ពាធណាមួយ) អាចផ្តល់នូវការយល់ព្រមពេញលេញ ដោយសេរី និងយល់ច្បាស់ចំពោះការធ្វើសម្ភាសន៍។

**សេចក្តីណែនាំ:**

- វាជាការប្រសើរបើយើងចាំអត្ថន័យលិខិតនេះ និងអាចនិយាយទៅកាន់អ្នកឱ្យសម្ភាសន៍។ ធ្វើយ៉ាងនេះមើលទៅហាក់ដូចជាសាមញ្ញ និងស្និទស្នាលដោយមិនស្មុគស្មាញជាមួយនឹងក្រដាសស្នាមឡើយ។
- ប្រសិនបើអ្នកឱ្យធ្វើបទសម្ភាសន៍មានបំណងផ្អាក ផ្លាស់ប្តូរទីកន្លែង ឬគ្មានបំណងបន្តការធ្វើសម្ភាសន៍នេះទៀតទេ យើងត្រូវគោរពនូវឆន្ទៈរបស់គាត់។
- ការធ្វើសម្ភាសន៍អាចធ្វើទៅបានដរាបណាអ្នកឱ្យធ្វើសម្ភាសន៍យល់ព្រមទាំងស្រុងដោយគ្មានការបង្ខិតបង្ខំ។
- អ្នកផ្តល់សម្ភាសន៍អាចយកអ្នកទៅសម្ភាសន៍ ឬនរណាម្នាក់ទៀតដែលគាត់ជឿទុកចិត្ត ជាសាក្សីក្នុងការយល់ព្រមដោយផ្ទាល់មាត់នេះ។ អាជ្ញាធរមិនគួរមានវត្តមាននៅទីនេះទេ ព្រោះថាគាត់អាចធ្វើឱ្យអ្នកផ្តល់សម្ភាសន៍មានអារម្មណ៍រារែក។
- អ្នកធ្វើសម្ភាសន៍ម្នាក់ទៀតដែលធ្វើសាក្សីនោះក៏មិនត្រូវមានវត្តមានការសម្ភាសន៍នេះដែរ។ បន្ទាប់ពីសម្ភាសន៍រួច អ្នកឱ្យសម្ភាសន៍ចាកចេញទៅ អ្នកសម្ភាសន៍និងសាក្សីត្រូវចុះហត្ថលេខាលើទម្រង់នេះហើយភ្ជាប់ជាមួយគោលការណ៍ណែនាំសម្ភាសន៍ ឬកំណត់ហេតុ។

**ការណែនាំខ្លួន**

ជម្រាបសួរ ខ្ញុំឈ្មោះ ...................... ខ្ញុំជា.............................. ខ្ញុំមកទីនេះដើម្បី.....................................

**សេចក្តីពន្យល់ពីដំណើរការនៃការសម្ភាសន៍**

យើងខ្ញុំសុំពេលវេលារបស់លោកប្រហែល៣០នាទី ដើម្បីសួរសំណួរមួយចំនួនអំពី ............ [ពន្យល់ពីគោលបំណងនៃកិច្ចសម្ភាសន៍]។ នៅពេលដែលយើងកំពុងតែសម្ភាសន៍ ប្រសិនជាអ្នកចង់បញ្ឈប់កិច្ចសម្ភាសន៍សូមប្រាប់ឱ្យយើងដឹងយើងខ្ញុំនឹងបញ្ឈប់តាមសំណូមពរ។

**មូលហេតុនៃការសម្ភាសន៍**

យើងធ្វើកិច្ចសម្ភាសន៍នេះដើម្បី ......................................................[ពន្យល់ពីមូលហេតុ]។

**មាតិការនៃកិច្ចសម្ភាសន៍**

ទាំងនេះជាអ្វីដែលយើងនឹងសួរអ្នក:.......................................[សង្ខេបពីសំនួរដែលត្រូវសួរ]។ យើងនឹងមិនសួរអ្នកពី..............[ពន្យល់ពីអ្វីយើងនឹងមិនសួរ ឧទាហរណ៍ បញ្ហាដែលគាត់បានជួបប្រទះក្នុងហេតុការណ៍ជួញដូរថ្មីៗនេះដោយហេតុថាវាអាចបង្កឱ្យជម្ងឺផ្លូវចិត្តរបស់គាត់ទទួលរងការប៉ះពាល់ថ្មី]។

**ការប្រើប្រាស់ព័ត៌មាន**

យើងនឹងប្រើប្រាស់ព័ត៌មានដែលអ្នកផ្តល់ឱ្យដើម្បីតែ.................[ពន្យល់ពីការប្រើប្រាស់ និងអ្នកទទួលព័ត៌មានទាំងនោះ]។ ប្រសិនជាយើងបោះពុម្ពផ្សាយ ឬផ្តល់ព័ត៌មានទាំងនោះទៅឱ្យនរណាម្នាក់ទៀតដែលក្រៅពីយើងជំរាបជូនពីខាងលើ កិច្ចសម្ភាសន៍ នេះត្រូវរក្សាជាអនាមិកហើយគ្មាននរណាម្នាក់ដឹងពីសារបានរបស់កិច្ចពិភាក្សានេះឡើយ។

**ការរក្សាភាពសម្ងាត់**

អ្វីដែលអ្នកប្រាប់យើងនឹងរក្សាជាការសម្ងាត់។ គ្មាននរណាម្នាក់ដឹងថាអ្នកផ្តល់កិច្ចសម្ភាសន៍នេះឡើយ។ អ្នកមិនចាំបាច់ប្រាប់ឈ្មោះមកខ្ញុំទេ ប្រសិនមិនចង់ប្រាប់។ ទោះបីជាអ្នកប្រាប់ក៏ខ្ញុំមិនសរសេរចូលដែរ។ ខ្លឹមសារនៃកិច្ចសម្ភាសន៍នឹងយកទៅពិភាក្សាជាមួយតែ............[អ្នកដែលអាចទទួលយកព័ត៌មាននេះ]។ យើងខ្ញុំសន្យាថាអ្វីដែលអ្នកប្រាប់នឹងមិនត្រូវប្រាប់ទៅ អ្នកឯទៀតរួមទាំងបុគ្គលិករបស់កម្មវិធី មិត្តភក្តិ គ្រួសាររបស់អ្នក ឬអ្នកខាងក្រៅណាម្នាក់ឱ្យដឹងឡើយ។

**ការព្រួយបារម្ភពីសុវត្ថិភាព**

យើងចង់ធ្វើឱ្យប្រាកដថាអ្នកមានអារម្មណ៍សុវត្ថិភាព និងកក់ក្តៅសម្រាប់ការសម្ភាសន៍។ ប្រសិនជាអ្នកគិតថាការផ្តល់សម្ភាសន៍នេះអាចបង្កគ្រោះថ្នាក់ដល់អ្នកអ្នកដទៃទៀតនោះ សូមប្រាប់ឱ្យយើងខ្ញុំដឹងផង។ តើអ្នកមានការព្រួយបារម្ភពីបញ្ហាណាមួយពេលឱ្យខ្ញុំសម្ភាសន៍ដែរឬទេ? *[រង់ចាំស្តាប់ចម្លើយ។ ចូរបញ្ឈប់កិច្ចសម្ភាសន៍ប្រសិនប្រសិនបើចាំបាច់]*

**ការយល់ព្រមពីអ្នកដទៃ**

យើងទទួលបានការយល់ព្រមឱ្យធ្វើកិច្ចសម្ភាសន៍នេះពី...........................[បញ្ជីឈ្មោះអ្នកដែលអនុញ្ញាតដូចជាឪពុកម្តាយ ឬនាយកមណ្ឌលផ្តល់ជម្រក] ដែលយល់ព្រមឱ្យសម្ភាសន៍អ្នក។ ពួកគាត់រីករាយក្នុងការអនុញ្ញាតឱ្យមានកិច្ចសម្ភាសន៍នេះហើយអ្នកត្រូវបានអនុញ្ញាតឱ្យចូលរួមកធ្វើការពិភាក្សានេះ។ ប៉ុន្តែប្រសិនជាអ្នកនៅមានការមន្ទិល អ្នកអាចសួរពីនរណាម្នាក់ទៀតសិនក៏បាន។ តើអ្នកមានចង់និយាយជាមួយនរណាម្នាក់សិនមុនធ្វើការសម្ភាសន៍ឬទេ? *[រង់ចាំស្តាប់ចម្លើយ។ ចូរផ្អាកកិច្ចសម្ភាសន៍ប្រសិនបើចាំបាច់]*

**ភាពងាយស្រួលសម្រាប់អ្នកដែលយើងសម្ភាសន៍**

ប្រសិនជាពេលវេលាមិនទាន់សមរម្យ យើងអាចលើកទៅពេលក្រោយណាមួយដែលល្អជាងនេះ។ យើងចង់រកកន្លែងសម្រាប់ពិភាក្សាគ្នាឱ្យស្រួលមួយ ហើយគ្មាននរណាម្នាក់មករំខាន ដូច្នេះហើយបើពេលនេះ និងកន្លែងនេះមិនទាន់សមរម្យនោះប្រាប់ខ្ញុំ។ <u>តើនេះជាពេលសមស្របសម្រាប់សម្ភាសន៍ដែរឬទេ?</u> *[រង់ចាំស្តាប់ចម្លើយ។ ចូររៀបចំទីកន្លែង និងពេលវេលាសម្រាប់សម្ភាសន៍ប្រសិនបើចាំបាច់]*

**សំនួរ**

<u>តើអ្នកមានសំនួរអ្វីទាក់ទងនឹងការសម្ភាសន៍នេះទេ?</u>

**សុំអនុញ្ញាតិដើម្បីចាប់ផ្តើមសម្ភាសន៍**

<u>តើខ្ញុំអាចចាប់ផ្តើមកិច្ចសម្ភាសន៍ពេលនេះបានទេ?</u>

*[រង់ចាំស្តាប់ចម្លើយថាអាច ឬមិនអាច។ ចូរបញ្ឈប់កិច្ចសម្ភាសន៍ប្រសិនបើចាំបាច់]*

[រង់ចាំចំលើយថាតើគាត់យល់បព្រមឬមិនយល់ព្រម។បញ្ឈប់កិច្ចសម្ភាសន៍ប្រសិនអ្នកដែលយើងសម្ភាសន៍ស្នើសុំ]

**កិច្ចសម្ភាសន៍នេះត្រូវបានយល់ព្រមឱ្យសម្ភាសន៍ដោយមានសាក្សី :**

| | |
|---|---|
| អ្នកធ្វើសម្ភាសន៍/ សាក្សី | អ្នកធ្វើសម្ភាសន៍/ សាក្សី |
| កាលបរិច្ឆេទ | កាលបរិច្ឆេទ |

# ឧបសម្ព័ន្ធ ក៩

## ប្រការគួរ និងមិនគួរធ្វើរបស់ UNIAP នៅពេលបំពេញភារកិច្ច

១. **ធានាឱ្យបានចំពោះការយល់ព្រមដោយស្ម័គ្រចិត្ត** ចូរអនុវត្តតាមខ្លឹមសារគោលការណ៍ណែនាំសីលធម៌ ដើម្បីធានាឱ្យបាននូវការយល់ព្រមដោយស្ម័គ្រចិត្ត ពេញលេញ និងចូលរួមយ៉ាងពេញទំហឹងក្នុងការសិក្សាស្រាវជ្រាវរបស់អ្នក។

២. **ណែនាំខ្លួនអ្នក និងក្រុមការងាររបស់អ្នក**នៅរាល់មុនពេលធ្វើសម្ភាសន៍ ឬពិភាក្សា ហើយប្រាប់ត្រួសៗពីគោល បំណងនៃសំនួរ ឬកម្មវិធីរបស់អ្នក។ វាអាចជាការសន្ទនាគ្នាលេងធម្មតាសម្រាប់កិច្ចការនេះ។

៣. **សួរមួយសំនួរម្តងៗ** ជាពិសេសនៅពេលមានអ្នកបកប្រែភាសា ហើយប្រើពាក្យ និងវេយ្យាករណ៍សាមញ្ញងាយយល់

៤. ត្រូវចាត់ទុកអ្នកដែលអ្នកកំពុងសម្ភាសន៍ដូចជាមិត្តភក្តិ។ **ត្រូវជួយឱ្យគាត់មានអារម្មណ៍ធម្មតា ហើយពេលនិយាយជាមួយគាត់ត្រូវសម្លឹងមើគាត់ដោយយកចិត្តទុកដាក់**។ ប្រើប្រាស់ពាក្យពេចន៍ដែលគាត់ងាយយល់ កុំសម្លឹងមើលតែអ្នកបកប្រែតែម្នាក់គត់នោះ។

៥. ត្រូវមានភេសជ្ជៈនិងអាហារ និង**ព្យាយាមរក្សាបរិយាកាសធម្មតា**។

៦. **មិនត្រូវសន្មតទេ**។ជៀសវាងការប្រើប្រាស់បទពិសោធន៍ចាស់របស់អ្នក និងការសន្មតផ្ទាល់ខ្លួនរបស់អ្នក រារាំងអ្នកក្នុងការសួរយកព័ត៌មានដោយមិនលំអៀង។ ហើយចូរស្តាប់នូវអ្វីដែលជាព្រឹត្តិការណ៍ទាំងអស់ពាក់ព័ន្ធជុំវិញបញ្ហាដែល លោកអ្នកចង់ដឹងផងដែរ។

៧. **ចូរប្រើវិធីសាស្ត្រសួរសំនួរផ្សេងៗគ្នា។** ជាដំបូងប្រើសំនួរបើកដើម្បីស្វែងយល់ពីអារម្មណ៍ និងអាកប្បកិរិយា បន្ទាប់មកប្រើសំនួរចំៗដើម្បីទាញយកចម្លើយលម្អិតជាងមុន។ នៅពេលអ្នកឆ្លើយប្រាប់អស់អ្វីត្រូវឆ្លើយប្តូរទៅប្រធានបទបន្ទាប់ផ្សេងទៀត។

៨. **ចៀសវាងមានគ្នាច្រើននាក់សួរសំណួរ**ក្នុងពេលតែមួយ។ ប្រសិនបើការសន្ទនាចាកពីប្រធានបទដែលលោកអ្នកចង់ពិភាក្សានោះសូមបណ្តោយឱ្យវាទៅតាមធម្មតាទៅចុះដោយមិនបាច់បង្ខំសួរទៀតឡើយ។ សម្រាប់សំណួរណាដែលមិនទាន់បានចម្លើយនោះត្រូវកត់ត្រាហើយចាំសាកសួរនៅពេលបន្ទាប់ម្តងទៀត។

៩. អ្នកបកប្រែគួរបកប្រែសំនួរ និងចំលើយឱ្យបានល្អ។ **គេគួរតែជៀសវាងពីការឱ្យចម្លើយជំនួសបុគ្គល**នោះ ទោះបីខ្លួនមានចំណេះដឹង និងបទពិសោធន៍លើបញ្ហានោះយ៉ាងណាក៏ដោយ។ ចំណេះដឹងរបស់គេអាចយកមកប្រើបន្ទាប់ពីកិច្ចសម្ភាសន៍នេះ។

១០. **កុំនិយាយកាត់សម្តីអ្នកផ្តល់សម្ភាសន៍កំពុងនិយាយ** កុំបញ្ចប់ឃ្លារបស់គាត់។ ព្រោះថាយើងមិនអាចដឹងថាមានព័ត៌មានអ្វីបន្ថែមផ្សេងទៀតពីការនិយាយរបស់គាត់នោះទេ ម្យ៉ាងវិញទៀតវាជារឿងខ្វះសុជីវធម៌ក្នុងការនិយាយកាត់អ្នកដទៃផងដែរ។

១១. មិនលើកតំកើងខ្លួន តែត្រូវរួសរាយរាក់ទាក់។ អ្នកដែលអ្នកសម្ភាសន៍ចំណាយពេលវេលារបស់គាត់ និងអ្វីដែលគាត់បានដឹង ដូច្នេះសួរតែអ្វីដែលអ្នកចង់ដឹង។ **កុំឱ្យគាត់អង្គុយចាំស្តាប់ការសន្ទនា ឬការពិភាគ**ជាមួយអ្នករួមការងារដោយភាសាមួយគាត់មិនអាចយល់អំពីអ្វីដែលអ្នកកំពុងនិយាយ។

១២. ប្រសិនជាអ្នកដែលយើងសម្ភាសន៍ងាយទទួលការប៉ះទង្គិច **ចូរសួរសំនួរបែបប្រយោល** ដើម្បីរកពន្លឺសម្រាប់អ្វីដែលយើងចង់ដឹង។ ជាពិសេសនៅពេលនិយាយដល់មន្ត្រីរដ្ឋអំណាច ឬអ្នកដែលរងគ្រោះធ្ងន់ធ្ងរពីការកេងប្រវ័ញ្ច។

១៣. ជាការប្រសើរ ចូរ**ប្រើប្រាស់ពាក្យពេចន៍ឱ្យដូចគ្នាជាមួយអ្នកដែលយើងសម្ភាសន៍កំពុងប្រើ។** ឧទាហរណ៍ ប្រសិនបើគាត់ប្រើពាក្យឈ្មួញកណ្តាល សូមកុំប្រើពាក្យដដែលទៅជា ភ្នាក់ងារ, មេខ្យល់ ឬអ្នកជួញដូរឱ្យសោះ។

១៤. មិនត្រូវសួរសំនួរប្រាសចាកពីក្រមសីលធម៌។ ត្រូវកំណត់ឱ្យច្បាស់ប្រភេទសំនួរដែលចាំបាច់ និងមិនចាំបាច់មុនពេលសម្ភាសន៍។ ការសួរសំនួរដែលទាក់ទិងនឹងការធ្វើទារុណកម្ម ការវាយដំលើរាងកាយ ការរំលោភផ្លូវភេទ អាចធ្វើឱ្យជនរងគ្រោះតក់ស្លុតសារជាថ្មី ហើយសំនួរទាំងនេះជាទូទៅមិនចាំបាច់ ឬមិនទាក់ទងនឹងការសិក្សាស្រាវជ្រាវ ឬធ្វើកម្មវិធីដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សទេ។ ព័ត៌មានបែបនេះគួរតែទុកឱ្យអ្នកជំនាញផ្នែកប្រឹក្សាពិគ្រោះយោបល់ ឬចិត្តវិទូ និងដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវសួរនាំវិញ។

១៥. ត្រូវស្គាល់ពីវប្បធម៌របស់អ្នកឱ្យសម្ភាសន៍។ ឧទាហរណ៍ នៅប្រទេសជាច្រើននៅមហាអនុតំបន់ទន្លេមេគង្គ ចាត់ទុកថាការអង្គុយសណ្តូកជើងដាក់ទៅកាន់អ្នកដទៃជារឿងមិនសមរម្យទេ។ ដូច្នេះចូរអង្កេត និងធ្វើតាមរបៀបរស់នៅរបស់ប្រជាជនក្នុងតំបន់: រួមមានរបៀបអង្គុយ របៀបដាក់ដៃ កាយវិការ របៀបឈរ ព្រមទាំងរបៀបនិយាយ និងការប្រើក្រសែភ្នែកផងទើបជាការប្រសើរ។



គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

ការិយាល័យគ្រប់គ្រងប្រចាំតំបន់  អាគារសហប្រជាជាតិ

អាគារ  ខ  ជាន់ទី៧មហាវិថី  Rajadamnern Nok

ទីក្រុងបាងកក  ១០២០០  ប្រទេសថៃ

គេហទំព័រ  www.no-trafficking.org